01426837

E443/10

**Declassified to Public**
**05 April 2019**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 03 / 2017
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| **ចំពោះមុខ** | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Claudia FENZ** |
| | ចៅក្រម **យូរ ឧត្តរា** |
| **កាលបរិច្ឆេទ** | ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៧ |
| **ភាសាដើម** | ខ្មែរ/អង់គ្លេស/បារាំង |
| **ចំណាត់ថ្នាក់ឯកសារ** | សម្ងាត់ |

---

# សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា សុំស្តាប់សក្ខីកម្មសាក្សីបន្ថែម អនុលោមតាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុង (ឯកសារ E391, E392, E395, E412 និង E426) (សំអាងហេតុពេញលេញ)

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ពេជ អង្គ
Marie GIRAUD

**<u>ជនជាប់ចោទ</u>**
នួន ជា
ខៀវ សំផន

**<u>មេធាវីជនជាប់ចោទ</u>**
សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្ដីផ្ដើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើសុំចំនួន ៥ របស់មេធាវីការពារក្ដី នួន ជា ដែលបានដាក់ អនុលោមតាមវិធាន ៨៧(៤) និងវិធាន ៩១(១) នៃវិធានផ្ទៃក្នុង ដើម្បីស្ដាប់សក្ខីកម្មសាក្សីបន្ថែមសរុបចំនួន ៤៥ រូប និងដើមបណ្ដឹងរដ្ឋប្បវេណីបន្ថែមចំនួន ១ រូប ក្នុងអំឡុងពេលសវនាការលើប្រធានបទស្ដីពីមន្ទីរសន្ដិសុខ និងការបោសសម្អាតផ្ទៃក្នុង។ នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចលើសំណើសុំទាំង ៥ នោះ ដោយចេញសំអាងហេតុតាមក្រោយ[1]។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសូមផ្ដល់សំអាងហេតុចំពោះសេចក្ដី-សម្រេចលើសាក្សីបន្ថែមនេះ។

## ២. សាវតារ

២. នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ មេធាវីការពារក្ដី នួន ជា បានដាក់សំណើទីមួយរបស់ខ្លួន ដែលក្នុងនោះមានទាំងសំណើសុំស៊ើបអង្កេតបន្ថែម អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង។ នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់ចម្លើយតបដោយស្នើសុំឱ្យអង្គជំនុំជម្រះស្វែងរកការបញ្ជាក់បំភ្លឺ ថាតើភស្តុតាងដែលបានស្នើឡើងនោះមាន

---

[1] សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដី នួន ជា សុំឱ្យស្ដាប់សក្ខីកម្មសាក្សីបន្ថែម អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E391, E392, E395, E412 និង E426) ឯកសារ E443 ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦ ("សេចក្ដីសម្រេចលើសាក្សីបន្ថែម") (សម្ងាត់)។ សំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧ (៤) សុំកោះហៅសាក្សីបន្ថែម និងសំណើអនុលោមតាមវិធាន ៩៣ សុំបំពេញកិច្ចស៊ើបសួរបន្ថែម ទាក់ទងនឹងវគ្គសវនាការនៅក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹងមន្ទីរសន្ដិសុខ ស-២១ និង ការបោសសម្អាតផ្ទៃក្នុង ឯកសារ E391 ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ ("សំណើទីមួយ") (សម្ងាត់)។ សំណើទីពីររបស់ នួន ជា សុំកោះហៅសាក្សីសម្រាប់សំណុំរឿង ០០២/០២ ទាក់ទងនឹងផ្នែកមន្ទីរសន្ដិសុខ និង ការបោសសម្អាតផ្ទៃក្នុង (មេដឹកនាំ) ឯកសារ E392 ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ("សំណើទីពីរ") (សម្ងាត់)។ សំណើទីបីរបស់ នួន ជា សុំកោះហៅសាក្សីសម្រាប់សវនាការលើសំណុំរឿង ០០២/០២ លើប្រធានបទស្ដីពី មន្ទីរសន្ដិសុខ និង ការបោសសម្អាតផ្ទៃក្នុង (ភស្តុតាងអំពីការបះបោរក្បត់) ឯកសារ E395 ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ ("សំណើទីបី") (សម្ងាត់)។ សំណើទីបួនរបស់ នួន ជា សុំកោះហៅសាក្សីសម្រាប់វគ្គមន្ទីរសន្ដិសុខ និង ការបោសសម្អាតផ្ទៃក្នុង ក្នុងសំណុំរឿង ០០២/០២ (ដំណើរការមន្ទីរសន្ដិសុខ ស-២១ និងភស្តុតាងជាឯកសារ) ឯកសារ E412 ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦ ("សំណើទីបួន") (សម្ងាត់)។ សំណើទីប្រាំរបស់ នួន ជា សុំកោះហៅសាក្សីនៅក្នុងសំណុំរឿង ០០២/០២ សម្រាប់វគ្គសវនាការស្ដីពីមន្ទីរសន្ដិសុខ និង ការបោសសម្អាតផ្ទៃក្នុង (ភស្តុតាងអំពីការបះបោរក្បត់ ការចាប់ខ្លួនតាមទំនើងចិត្ត និងមន្ទីរសន្ដិសុខ ស-២១) ឯកសារ E426 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦ ("សំណើទីប្រាំ") (សម្ងាត់)។

ទំនាក់ទំនងជាមួយនឹងដីកាដំណោះស្រាយដោយរបៀបណា[2]។ មិនមានភាគីណាមួយបានដាក់ចម្លើយតបឡើយ។

៣. នៅថ្ងៃទី ០១ និង ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្តី នួន ជា បានដាក់សំណើទីពីរ និងសំណើទីបី ទៅតាមកាលបរិច្ឆេទនីមួយៗ។ នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ចម្លើយតបរួមទៅនឹងសំណើទាំងពីរនេះ[3]។ មិនមានភាគីណាផ្សេងទៀតដាក់ចម្លើយតបឡើយ។

៤. នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦ ដោយកត់សម្គាល់ឃើញថា សំណើចំនួនបីរបស់មេធាវីការពារក្តី នួន ជា ស្នើសុំស្តាប់សក្ខីកម្មដែលទាក់ទងទៅនឹងក្រុមជម្លោះនៅក្នុងជួរថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យនោះ អង្គជំនុំជម្រះបានស្នើឲ្យមេធាវីការពារក្តី នួន ជា ដាក់សារណាអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ដោយពន្យល់ថាតើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទនឹងត្រូវប៉ះពាល់បែបណា ដោយសារភ័ស្តុតាងបន្ថែមដែលហាក់បង្ហាញពីអត្ថិភាពនៃក្រុមជម្លោះ ឬការបះបោរប្រឆាំង នៅក្នុងវិសាលភាពនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ដោយផ្តល់ឱកាសដល់ភាគីដទៃទៀតធ្វើការឆ្លើយតប[4]។

៥. នៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦ មេធាវីការពារក្តី នួន ជា បានដាក់សំណើទីបួនរបស់ខ្លួន។ នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦ សហមេធាវីនាំមុខបានដាក់ចម្លើយតប[5]។ មិនមានភាគីដទៃទៀតដាក់ចម្លើយតបនោះទេ។

---

[2] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីមួយរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) និងវិធាន ៩៣ ទាក់ទងការជំនុំជម្រះលើសំណុំរឿង ០០២/០២ ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ឯកសារ E391/1 ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ("ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីមួយ") កថាខណ្ឌ ២០។

[3] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីពីរ និងទីបី របស់ នួន ជា ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ឯកសារ E392/1 ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ("ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីពីរ និងសំណើទីបី")។

[4] សំណើសុំសារណាសង្ខេបស្តីអំពីសារៈសំខាន់នៃក្រុមជម្លោះនៅក្នុងថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ ឯកសារ E395/1 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦។

[5] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើលើកទីបួនរបស់ នួន ជា ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ឯកសារ E412/1 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦ ("ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីបួន")។

៦. នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦ ក្នុងការឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ដែលស្នើសុំឱ្យដាក់សារណាសង្ខេបនោះ មេធាវីការពារក្តី នួន ជា បានដាក់សារណាមួយ អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ស្តីពីភាពពាក់ព័ន្ធនៃការបះបោរក្បត់ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ[6]។ នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញា មេធាវីការពារក្តី ខៀវ សំផន និងសហមេធាវីនាំមុខ បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសារណារបស់មេធាវីការពារក្តី នួន ជា[7]។

៧. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦ មេធាវីការពារក្តី នួន ជា បានដាក់សំណើទីប្រាំរបស់ខ្លួន។ មិនមានភាគីណាមួយបានដាក់ចម្លើយតបនោះទេ។

## ៣. សារណា

### ៣.១. សំណើរបស់ នួន ជា

#### ៣.១.១. សំណើទីមួយ

៨. មេធាវីការពារក្តី នួន ជា ស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅសាក្សីចំនួន ៦ រូបបន្ថែមទៀត ដែលទាក់ទងទៅនឹងប្រធានបទស្តីពីមន្ទីរសន្តិសុខ ស-២១ ជាពិសេស សាក្សី ស្ហ៊ុយ សៅ (2-TCW-1029), ថាច សៀក (2-TCW-1030), សែម អំ (2-TCW-1031), វង់ វ៉ៃ (2-TCW-1032), ខឹម សំហួន (2-TCW-1033) និង ស្វ រ៉េន (2-TCW-1031)[8]។ មេធាវីការពារក្តីអះអាងថា សាក្សីទាំងនេះបានដឹងអំពីអត្ថិភាពនៃក្រុមជម្លោះ ឬ ជាប់ពាក់ព័ន្ធនឹង*រដ្ឋប្រហារ* ដែលបានប៉ុនប៉ងធ្វើឡើងដោយពួកគាត់ផ្ទាល់ ដូច្នេះហើយ ភ័ស្តុតាងរបស់ពួកគាត់ជាប់ពាក់ព័ន្ធទៅនឹងការបោសសម្អាត

---

[6] សេចក្តីសន្និដ្ឋានរបស់ នួន ជា ស្តីពីភាពពាក់ព័ន្ធនៃភ័ស្តុតាងពីការបះបោរក្បត់ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ក្នុងសំណុំរឿង ០០២/០២ ឯកសារ E395/2 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦ ("សេចក្តីសន្និដ្ឋានរបស់ នួន ជា")។

[7] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីសន្និដ្ឋានរបស់ នួន ជា ពាក់ព័ន្ធនឹងការបះបោរក្បត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ E395/3 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦។ ចម្លើយតបរបស់មេធាវីការពារក្តី ខៀវ សំផន ទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី នួន ជា ទាក់ទងនឹងភាពពាក់ព័ន្ធនៃអត្ថិភាពនៃការបះបោរ (E395/2) ឯកសារ E395/4 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦។ ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសារណារបស់ នួន ជា ស្តីពីភាពពាក់ព័ន្ធនៃភ័ស្តុតាងអំពីការបះបោរក្បត់ ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ក្នុងសំណុំរឿង ០០២/០២ ឯកសារ E395/5 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦។

[8] សំណើទីមួយ កថាខណ្ឌ ១, ៣៦។

ផ្ទៃក្នុង[9]។ សាក្សីទាំង ៦ រូបនេះ ស្ថិតនៅក្នុងផ្នែកនៃកងពល ១ ឬ កងពល ៣១០ ដែលដឹកនាំដោយ អឿន[10]។ យោងតាមមេធាវីការពារក្ដី សំណើនេះដាក់ទាន់ពេលវេលា ពីព្រោះ "តម្រូវការក្នុងការស្ដាប់សក្ខីកម្មសាក្សីទាំង ៦ រូបនេះ មានលក្ខណៈដាច់ខាត និងជាក់ស្ដែង បន្ទាប់ពីបញ្ចប់ការស្ដាប់សក្ខីកម្មរបស់ កែវ លឿ និង សែម ហឿន" ដែលវាបំលេចឱ្យឃើញថា អ្នកទាំងពីរ "អាចមានព័ត៌មានតិចតួច" អំពីការបះបោរ និងការប៉ុនប៉ងធ្វើរដ្ឋប្រហារ[11]។

៩. មេធាវីការពារក្ដី នួន ជា ក៏បានស្នើសុំអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែម ទាក់ទងនឹងអ្នកចុះចូលដែលបានចាកចេញពីប្រទេសកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយអាចផ្ដល់ព័ត៌មានទាក់ទងនឹងការប៉ុនប៉ងធ្វើរដ្ឋប្រហារ ដែលដឹកនាំដោយក្រុមប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ[12]។ ជាពិសេស មេធាវីការពារក្ដីបានស្នើសុំឱ្យអង្គជំនុំជម្រះកំណត់អត្តសញ្ញាណ និង ស្វែងរកអ្នកចុះចូល ដែលត្រូវបានលើកឡើងនៅក្នុងសៀវភៅរបស់ Ben Kiernan ដែលមានចំណងជើងថា *របប ប៉ុល ពត* ក៏ដូចជា បទសម្ភាសន៍ផ្សេងៗរបស់អ្នកទាំងនោះដែលអាចរកបាន[13]។ មេធាវីការពារក្ដី នួន ជា អះអាងថា ភ័ស្តុតាងនេះមានទំនាក់ទំនងជាមួយនឹងប្រធានបទស្ដីពីការបោសសម្អាតផ្ទៃក្នុង និងជាពិសេស មន្ទីរសន្តិសុខ ស-២១[14]។ ជាងនេះទៀត មេធាវីការពារក្ដីលើកឡើងថា ភ័ស្តុតាងនេះមានទំនាក់ទំនងទៅនឹងការអះអាងដែលថា ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ បានបែកខ្ញែកគ្នាជាក្រុមជម្លោះ ដែលក្រុមខ្លះទទួលបានការគាំទ្រជាសម្ងាត់ពីវៀតណាម ដែលអាច*ក្នុងចំណោមប្រការផ្សេងៗ* ប៉ះពាល់ដល់ការកំណត់ពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[15]។

### ៣.១.២. សំណើទីពីរ

---

[9] សំណើទីមួយ កថាខណ្ឌ ២៣។

[10] សំណើទីមួយ កថាខណ្ឌ ៧, ១២, ១៥, ១៧, ១៩, ២២។

[11] សំណើទីមួយ កថាខណ្ឌ ២៤។

[12] សំណើទីមួយ កថាខណ្ឌ ២៦។

[13] សំណើទីមួយ កថាខណ្ឌ ៣៦។

[14] សំណើទីមួយ កថាខណ្ឌ ៣៤។

[15] សំណើទីមួយ កថាខណ្ឌ ២៣, ៣៤។

១០. មេធាវីការពារក្តី នួន ជា បានស្នើសុំអនុលោមតាមវិធាន ៩១(១) នៃវិធានផ្ទៃក្នុង ឱ្យអង្គជំនុំជម្រះពន្លឿនការស្តាប់សក្ខីកម្មរបស់សាក្សីចំនួន ៥ រូប ដែលមេធាវីការពារក្តីបានស្នើសុំរួចហើយកាលពីពេលមុន ពោលគឺ ហេង សំរិន (2-TCW-831), អ៊ុក ប៊ុនឈឿន (2-TCW-951), ប៉ែន សុវណ្ណ (2-TCW-952), ប៉ុល សារឿន (2-TCW-962) និង មាស សឿន (2-TCW-917)[16]។ មេធាវីការពារក្តីក៏បានស្នើបន្ថែមឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញ លើសេចក្តីសម្រេចរបស់ខ្លួនដែលមិនកោះហៅសាក្សី ហ៊ុន សែន (2-TCW-1001) និង កា ដេវ (2-TCW-998)[17]។ ទាក់ទងនឹង កា ដេវ (2-TCW-998) មេធាវីការពារក្តីក៏បានស្នើសុំអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ឱ្យអង្គជំនុំ-ជម្រះស្តាប់ចម្លើយគាត់ ឬ ក៏អនុញ្ញាតឱ្យមេធាវីការពារក្តីស្តាប់ចម្លើយគាត់ ព្រោះតែនៅពេលបច្ចុប្បន្ននេះ ព័ត៌មានដែលទាក់ទងនឹងគាត់មានចំនួនតិចតួច[18]។ បើទោះបីជា មេធាវីការពារក្តីបានទទួលស្គាល់ថា សំណើសុំឱ្យពិចារណាឡើងវិញ ត្រូវមានយុត្តិកម្មដោយការបង្ហាញភ័ស្តុតាងថ្មី ឬមានកាលៈទេសៈថ្មីក៏ដោយ ក៏មេធាវីការពារក្តីស្នើថា អង្គជំនុំជម្រះគួរអនុវត្ត "លក្ខណៈវិនិច្ឆ័យទូលាយ [...] ដែលត្រូវបានអនុវត្តជាទូទៅនៅតុលាការ ICTY" ដែលរួមមាន កាលៈទេសៈដែលត្រូវបានយល់ឃើញថា សេចក្តីសម្រេចលើកមុនមានកំហុស ឬបណ្តាលឱ្យមានភាពអយុត្តិធម៌[19]។ ជាចុងក្រោយ មេធាវីការពារក្តី នួន ជា ស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅសាក្សីថ្មី ១ រូបឈ្មោះ គន់ គីម (2-TCW-1035) អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង និងស្តាប់ចម្លើយគាត់ អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ឬ ក៏អនុញ្ញាតឱ្យមេធាវីការពារក្តីស្តាប់ចម្លើយគាត់[20]។

១១. មេធាវីការពារក្តីអះអាងថា សាក្សីទាំង ៨ រូបគឺជា "មេដឹកនាំការបះបោរក្បត់ ដែលនៅរស់រានមានជីវិតដែលបានដឹកនាំដោយកម្មាភិបាល ប.ក.ក. ដែលបានផ្តាច់ខ្លួន ក្រោមការជួយជ្រោមជ្រែងពីវៀតណាម ប្រឆាំងនឹង ប.ក.ក. និងរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជាប្រជាធិបតេយ្យ ឬក៏ពួកគាត់អាចផ្តល់សក្ខីកម្មក្នុងនាមជាមេដឹកនាំការបះបោរ"[21]។ សាក្សីថ្មីតែ ១ រូប ដែលត្រូវបានស្នើសុំមានឈ្មោះ គន់ គីម (2-TCW-1035) ជាអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងត្រូវ

---

[16] សំណើទីពីរ កថាខណ្ឌ ២, ៣៧។

[17] សំណើទីពីរ កថាខណ្ឌ ២, ៨, ៣៧។

[18] សំណើទីពីរ កថាខណ្ឌ ៣៥។

[19] សំណើទីពីរ កថាខណ្ឌ ១៥-១៦។

[20] សំណើទីពីរ កថាខណ្ឌ ២, ៣៧។

[21] សំណើទីពីរ កថាខណ្ឌ ១។

បានចោទប្រកាន់ថាជាអតីតមេដឹកនាំនៃការបះបោរ[22]។ មេធាវីការពារក្តីអះអាងថា សំណើរបស់ខ្លួនបានដាក់ទាន់ពេលវេលា ពីព្រោះខ្លួនបានរង់ចាំការបញ្ជាក់ព័ត៌មានលម្អិតអំពី គន់ គីម (2-TCW-1035) នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់ វ៉ាន់ ម៉ាត់ (2-TCW-893) នៅថ្ងៃទី 0៩ ខែ មីនា ឆ្នាំ ២០១៦[23]។

### ៣.១.៣. សំណើទីបី

១២. មេធាវីកាពារក្តី នួន ជា ស្នើសុំអនុលោមតាមវិធាន ៩១(១) នៃវិធានផ្ទៃក្នុង ឱ្យអង្គជំនុំជម្រះពន្លឿនការស្តាប់សក្ខីកម្មរបស់សាក្សីចំនួន ៤ រូប ដែលមេធាវីការពារក្តីបានស្នើសុំរួចហើយកាលពីពេលមុន ពោលគឺ Robert LEMKIN (2-TCW-877), ចាន់ សាវុត (2-TCW-959), ថែល ឈឿន (2-TCW-960) និង អ៊ិន ធឿន (2-TCW-961)[24]។ មេធាវីការពារក្តីក៏បានលើកឡើងថា Robert LEMKIN (2-TCW-877) ជាសាក្សីសំខាន់របស់មេធាវីការពារក្តី ហើយសក្ខីកម្មរបស់គាត់មានសារៈសំខាន់ក្រៃលែង ពីព្រោះ ថេត សម្បត្តិ (2-TCW-885) មានចេតនាមិនសហការជាមួយ អ.វ.ត.ក. ទេ[25]។ មេធាវីការពារក្តីអះអាងផងដែរថា សក្ខីកម្មរបស់ ចាន់ សាវុត (2-TCW-959), ថែល ឈឿន (2-TCW-960) និង អ៊ិន ធឿន (2-TCW-961) មានសារៈសំខាន់ក្រៃលែង ព្រោះ ថេត សម្បត្តិ (2-TCW-885) មានចេតនាមិនបង្ហាញអត្តសញ្ញាណបុគ្គលចំនួន ៤ រូប ដែលគាត់ និង Robert LEMKIN (2-TCW-877) បានសម្ភាសន៍។ ភស្តុតាងរបស់ពួកគេត្រូវបានកំណត់ថា បានផ្តោតលើ "ការរៀបចំ និងការប៉ុនប៉ងក្នុងការបះបោរក្បត់នៅភូមិភាគពាយ័ព្យ"[26]។

១៣. មេធាវីការពារក្តីក៏បានស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅសាក្សីថ្មីចំនួន ៧ រូប អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ពោលគឺ ទាត់ ធឿន (2-TCW-829), ឈន វន (2-TCW-1036), ហ្លួន ជឿម (2-TCW-1037), សាម៉ី សារ៉ែង (2-TCW-1038), ឈ្លួម សារ៉ឺន (2-TCW-1039), ម៉ី សារឿន (2-TCCP-1040) និង អន សុភាព (2-TCW-1041)[27]។ ចំពោះសាក្សី ៥ រូបដំបូងដែល

---

[22] សំណើទីពីរ កថាខណ្ឌ ២៩។

[23] សំណើទីពីរ កថាខណ្ឌ ៣១។

[24] សំណើទីបី កថាខណ្ឌ ២។

[25] សំណើទីបី កថាខណ្ឌ ២៣។

[26] សំណើទីបី កថាខណ្ឌ ២៤-២៥។

[27] សំណើទីបី កថាខណ្ឌ ២។

ជាអតីតកម្មាភិបាលភូមិភាគពាយ័ព្យ មេធាវីការពារក្ដីសូមយោងទៅលើសារណានានារបស់ខ្លួន នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ចំពោះភាពជាប់ពាក់ព័ន្ធនៃសក្ខីកម្មរបស់ពួកគេ ដោយកត់សម្គាល់ថា កំណត់ហេតុនៃការស្ដាប់ចម្លើយរបស់ពួកគេ ត្រូវបានទទួលយកជាភស្តុតាងរួចហើយ[28]។ សាក្សីទាំងនេះត្រូវបានរំពឹងថានឹងផ្ដល់ភស្តុតាងលើ "ការរៀបចំ និងការប៉ុនប៉ងក្នុងការបះបោរក្បត់នៅភូមិភាគពាយ័ព្យ ការរីករវផ្ទៃក្នុង និងអត្ថិភាពនៃក្រុមផ្សេងៗគ្នានៅក្នុង ប.ក.ក. និងរចនាសម្ព័ន្ធ និងប្រតិបត្តិការនៃភូមិភាគពាយ័ព្យ"[29]។ មេធាវីការពារក្ដី នួន ជា ក៏ស្នើសុំស្ដាប់សក្ខីកម្ម ម៉ី សារឿន (2-TCCP-1040) ដែលត្រូវបានកំណត់អត្តសញ្ញាណជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង 00៤[30]។ គាត់ធ្វើការនៅកសិដ្ឋានមួយនៅខេត្តព្រៃវែង ហើយកំណត់ហេតុនៃការ ស្ដាប់ចម្លើយរបស់គាត់បានពិពណ៌នាអំពីការចូលរួមរបស់គាត់នៅក្នុងការបះបោរផ្ទៃក្នុងដែលដឹកនាំដោយ សោ ភឹម ជាលេខាភូមិភាគបូព៌ា ដែលបានប្រមូលផ្ដុំកម្លាំងប្រឆាំងនឹង ប៉ុល ពត។ គាត់ក៏បានផ្ដល់ព័ត៌មានអំពីកម្លាំង ប.ក.ក. ដែលបានចាប់ផ្ដើមវាយប្រហារតាមយន្តហោះ និងរថក្រោះ ការបង្ក្រាបការបះបោរ និងការធ្វើអត្តឃាតរបស់ សោ ភឹម[31]។ ជាចុងក្រោយ មេធាវីការពារក្ដីស្នើសុំស្ដាប់សក្ខីកម្ម អន សុភាព (2-TCW-1041) ដែលជាអតីតកម្មាភិបាលភូមិភាគព្ញសាន និងជាប្រពន្ធរបស់ នោម សែ (2-TCW-840) ដែលត្រូវបានកំណត់ពេលឱ្យមកផ្ដល់សក្ខីកម្មក្នុងសំណុំរឿង 00២/0២ ប៉ុន្តែគាត់បានទទួលមរណភាព[32]។

១៤. មេធាវីការពារក្ដីអះអាងថា សាក្សីទាំង ១១ រូបផ្ដល់ភស្តុតាងអំពី "ការបះបោរក្បត់ដែលបានដឹកនាំដោយកម្មាភិបាល ប.ក.ក. ដែលបានផ្ដាច់ខ្លួន ដោយមានការជួយជ្រោមជ្រែងពីវៀតណាម ប្រឆាំង ប.ក.ក. និងរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជាប្រជាធិបតេយ្យ" ហើយពួកគេអាចផ្ដល់សក្ខីកម្មអំពីហេតុការណ៍នានានៅភូមិភាគពាយ័ព្យ ភូមិភាគបូព៌ា និងភូមិភាគព្ញសាន[33]។ មេធាវីការពារក្ដីស្នើ

[28] សំណើទីបី កថាខណ្ឌ ២៦។

[29] សំណើទីបី កថាខណ្ឌ ២៨។

[30] សំណើទីបី កថាខណ្ឌ ៣១។

[31] សំណើទីបី កថាខណ្ឌ ៣២-៣៤។

[32] សំណើទីបី កថាខណ្ឌ ៣៦, ៣៨។

[33] សំណើទីបី កថាខណ្ឌ ១, ២១-២២។

សុំឱ្យពួកគេបង្ហាញខ្លួននៅចំពោះមុខតុលាការ មុនការផ្ដល់សក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច (2-TCW-916)[34]។

១៥. មេធាវីការពារក្ដីអះអាងថា សំណើនេះបានដាក់ទាន់ពេលវេលា ពីព្រោះវាជាការសមស្របក្នុងការរង់ចាំរហូតដល់បញ្ចប់ប្រធានបទស្ដីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង មុននឹងវាយតម្លៃថាតើ ខ្លួនត្រូវស្នើសុំកោះហៅសាក្សីបន្ថែមទាក់ទងនឹងការបះបោរក្បត់ និងការប៉ុនប៉ងធ្វើរដ្ឋប្រហារ ដែរ ឬ យ៉ាងណា[35]។ មេធាវីការពារក្ដីលើកឡើងបន្ថែមទៀតថា ខ្លួនរង់ចាំសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថាតើសាក្សីចំនួន ៣ រូបក្នុងចំណោមសាក្សីដែលបានស្នើសុំ រួមមាន ទាត់ ធឿន (2-TCW-829) (ក្នុងនាមជាសាក្សីរំលឹកលើអង្គហេតុ), ឈន វន (2-TCW-1036) និង ហួន ជឿម (2-TCW-1037) នឹងត្រូវកោះហៅនៅក្នុងដំណាក់កាលបណ្ដឹងសាទុក្ខ ដែរ ឬទេ ដែលសេចក្ដីសម្រេចនេះបានចេញនៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ដោយបានបដិសេធសំណើសុំស្ដាប់សក្ខីកម្មរបស់ពួកគេ[36]។

### ៣.១.៤. សំណើទីបួន

១៦. មេធាវីការពារក្ដី នួន ជា បានស្នើសុំអនុលោមវិធាន ៩១(១) នៃវិធានផ្ទៃក្នុង ឱ្យអង្គជំនុំជម្រះពន្លឿនការស្ដាប់សក្ខីកម្មរបស់សាក្សីចំនួន ៧ រូប ដែលមេធាវីការពារក្ដីបានស្នើសុំរួចហើយកាលពីពេលមុន រួមមានឈ្មោះ ម៉ម ណៃ (2-TCW-864), នឹម គឹមស្រ៊ាង (2-TCW-854), លី ហ៊ាវ (2-TCW-956), Walter HEYNOWSKI (2-TCW-946), ឆាំង យុ (2-TCW-870), ឃិន នាន (2-TCW-963) និង ជ័យ សុភារ៉ា (2-TCW-81)[37]។ មេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះស្ដាប់សក្ខីកម្មសាក្សី ៣ រូប បន្ថែមទៀត អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងដែលមានឈ្មោះ ហ៊ិន សុជានី (2-TCW-1042) និង Hiroto FUJIWARA (2-TCW-1043) ដែលអ្នកទាំងពីរធ្លាប់ធ្វើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស.) និងជាអ្នករៀបចំបញ្ជីឈ្មោះអ្នកទោសមន្ទីរ ស-២១ ព្រមទាំង នួន ម៉ាលី (2-TCW-1044) ដែលបានផ្ដល់រូបថតមួយចំនួនរបស់

[34] សំណើទីបី កថាខណ្ឌ ៣, ៤១។

[35] សំណើទីបី កថាខណ្ឌ ២៩។

[36] សំណើទីបី កថាខណ្ឌ ៣០, ៣៥, ៤០។

[37] សំណើទីបួន កថាខណ្ឌ ១-២, ៣៧។

មន្ទីរ ស-២១ ជូនដល់មជ្ឈមណ្ឌលឯកសារកម្ពុជា[38]។ គោលជំហររបស់មេធាវីការពារក្ដី នួន ជា គឺថា បុគ្គលភាគច្រើនដែលត្រូវបានចោទប្រកាន់ថាបានចុះឈ្មោះនៅមន្ទីរ ស-២១ មិនបានជាប់ឃុំ ឬ សម្លាប់នៅមន្ទីរ ស-២១ នោះទេ[39]។ មេធាវីការពារក្ដីអះអាងថា ការពិនិត្យទៅលើបញ្ជីអ្នកទោសនៅមន្ទីរ ស-២១ ដែលត្រូវបានទទួលយកជាភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ បានបង្កើត "ចម្ងល់យ៉ាងខ្លាំងអំពីវិធីសាស្ត្រដែលបានយកមកប្រើប្រាស់ ដើម្បីចងក្រងបញ្ជីឈ្មោះនេះ" និងអំពី "ប្រភពដើម កាលបរិច្ឆេទ និងសុក្រិតភាពទូទៅ" នៃឯកសារនានាដែលបានយកមកធ្វើជាសំអាងនៅក្នុងការរៀបចំបញ្ជីនេះ[40]។ ដូច្នេះ មេធាវីការពារក្ដី នួន ជា អះអាងថា វាមានសារៈសំខាន់ណាស់ក្នុងការស្ដាប់សក្ខីកម្មរបស់ ហ៊ិន សុធានី (2-TCW-1042) និង Hiroto FUJIWARA (2-TCW-1043) ដែលបានធ្វើបញ្ជីឈ្មោះនេះអស់រយៈពេលពីរឆ្នាំ[41]។ ស្រដៀងគ្នានេះដែរ មេធាវីការពារក្ដីបានស្នើសុំឱ្យកោះហៅ នួន ម៉ាលី (2-TCW-1044) មកផ្ដល់សក្ខីកម្មអំពីយថាភាព និងដំណើរការនៃការរក្សាទុករូបថតដែលបានដាក់នៅក្នុងបញ្ជីឧបសម្ព័ន្ធ ដែលត្រូវបានទទួលយកជាឯកសារភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ និងដាក់លេខឯកសារ E3/9214។ មេធាវីការពារក្ដីអះអាងថា សក្ខីកម្មរបស់សាក្សីនេះ គឺជាវិធីតែមួយគត់ដើម្បីយល់ដឹងពីបរិបទនៃការទទួលបានរូបថត និងការបញ្ជូនរូបថតទៅមជ្ឈមណ្ឌលឯកសារកម្ពុជា[42]។ ជាចុងក្រោយ មេធាវីការពារក្ដីលើកឡើងថា សំណើនេះបានដាក់ទាន់ពេលវេលា ពីព្រោះបញ្ជីឈ្មោះអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស. បានដាក់បង្ហាញទៅដល់ភាគីនានា នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦ ហើយសហព្រះរាជអាជ្ញាបានដាក់សំណើសុំបន្ថែមរូបថតមន្ទីរ ស-២១ ទៅក្នុងឧបសម្ព័ន្ធឯកសារ E3/9214 នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦[43]។

### ៣.១.៥. សំណើទីប្រាំ

១៧. មេធាវីការពារក្ដី នួន ជា ស្នើឱ្យអង្គជំនុំជម្រះស្ដាប់សក្ខីកម្មរបស់សាក្សីថ្មីចំនួន ១១ រូប អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង និងទទួលយកធ្វើជាឯកសារភ័ស្តុតាងនូវចម្លើយសាក្សីចំនួន ៥

[38] សំណើទីបួន កថាខណ្ឌ ៣, ៣៧។

[39] សំណើទីបួន កថាខណ្ឌ ៤។

[40] សំណើទីបួន កថាខណ្ឌ ៣៣-៣៤។

[41] សំណើទីបួន កថាខណ្ឌ ៣៤។

[42] សំណើទីបួន កថាខណ្ឌ ៣៥។

[43] សំណើទីបួន កថាខណ្ឌ ៣៥-៣៦។

របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលទាក់ទងទៅនឹងសាក្សីចំនួន ៥ រូប ដែលបានស្នើឡើង[44]។ មេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅ សាក្សីលេខ ៤ (2-TCW-1052) និង ឡុង វុន (2-TCW-971) មកផ្ដល់សក្ខីកម្មទាក់ទងទៅនឹងជម្លោះផ្ទៃក្នុងនៅភូមិភាគពាយ័ព្យ ដែលទាក់ទងនឹងប្រធានបទស្ដីពីការបោសសម្អាតផ្ទៃក្នុង។ សាក្សីលេខ ៤ ជាសាក្សីអនាមិកដែលត្រូវបានសម្ភាសន៍ដោយ Robert LEMKIN (2-TCW-877) និង ថេត សម្បត្តិ (2-TCW-885) សម្រាប់ភាពយន្តរបស់ពួកគេដែលមានចំណងជើងថា *សត្រូវប្រជាជន*[45]។ យោងតាម Robert LEMKIN (2-TCW-877) សាក្សីនេះជាមេបញ្ជាការកងទ័ពមួយរូបដែលបានចូលរួមវាយចូលកាន់កាប់ទីក្រុងភ្នំពេញ នៅខែ មេសា ឆ្នាំ ១៩៧៥ ហើយក្រោយមកជាផ្នែករដ្ឋបាលរបស់ភូមិភាគពាយ័ព្យក្រោមការបញ្ជាផ្ទាល់ពី ប៉ុល ពត។ មេធាវីការពារក្ដីអះអាងថា គាត់ផ្ដល់ការពិពណ៌នាពិសេសអំពីស្ថានភាពវិករវ ដែលគាត់អាចសង្កេតឃើញយ៉ាងជាក់លាក់នៅក្នុងភូមិភាគពាយ័ព្យ ដែលនៅទីនោះប្រជាជនជួបប្រទះគ្រោះអត់ឃ្លាន ត្រូវបានបង្ខំឱ្យធ្វើការហួសកម្លាំង និងត្រូវបានសម្លាប់ជាទ្រង់ទ្រាយធំ ដែលបំពានទៅនឹងមាគ៌ាបក្ស[46]។ ដោយសារ សាក្សីលេខ ៤ បានស្នើសុំចាត់ថ្នាក់ជាសាក្សីសម្ងាត់បំផុត នោះមេធាវីការពារក្ដីក៏បានស្នើសុំឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញធ្វើការវាយតម្លៃពីហានិភ័យ ដោយអនុលោមតាមវិធាន ២៩(៣) នៃវិធានផ្ទៃក្នុង ដើម្បីផ្ដល់នូវវិធានការការពារដែលចាំបាច់[47]។ មេធាវីការពារក្ដីអះអាងថា ឡុង វុន (2-TCW-971) ត្រូវបានបញ្ជូនទៅធ្វើការនៅក្នុងភូមិភាគពាយ័ព្យ ហើយគាត់អាចពិពណ៌នាអំពីលក្ខខណ្ឌរស់នៅរបស់ប្រជាជននៅទីនោះ[48]។ មេធាវីការពារក្ដីលើកឡើងថា សាក្សីរូបនេះអាចផ្ដល់ការយល់ដឹងពិសេសពាក់ព័ន្ធនឹងផលវិបាកនៃគោលនយោបាយនានា ដែលបានអនុវត្តដោយអតីតកម្មាភិបាលភូមិភាគពាយ័ព្យ និងភាពខុសគ្នារវាងគោលនយោបាយទាំងនោះជាមួយនឹងមាគ៌ាបក្ស[49]។

---

[44] សំណើទីប្រាំ កថាខណ្ឌ ១, ៨១។ ឯកសារទាំងនេះជាការសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹងសាក្សីដែលបានស្នើសុំ មានឈ្មោះ ម៉ូវ សុង (2-TCW-1053), ប៊ុត រុំ (2-TCW-1054), ខាន់ ប៉ត (2-TCW-1055), ទុយ ប៉េងឈន (2-TCW-1056) និង គុប ឡូញ (2-TCW-1059)។

[45] សំណើទីប្រាំ កថាខណ្ឌ១៣។

[46] សំណើទីប្រាំ កថាខណ្ឌ ១៣។

[47] សំណើទីប្រាំ កថាខណ្ឌ ១៥, ៨១។

[48] សំណើទីប្រាំ កថាខណ្ឌ ១៦។

[49] សំណើទីប្រាំ កថាខណ្ឌ ១៧។

១៨. មេធាវីការពារក្ដី នួន ជា បានស្នើសុំបន្ថែមទៀតឲ្យអង្គជំនុំជម្រះស្ដាប់សក្ខីកម្មសាក្សីចំនួន ៥ រូប ដែលទាក់ទងនឹងការបះបោរក្បត់របស់កម្មាភិបាលភូមិភាគបូព៌ា។ ម៉ូវ សុង (2-TCW-1053) ជាពេទ្យនៅក្នុងកងពល ៧០៣ និងបានផ្ដល់ព័ត៌មានទាក់ទងនឹងការបះបោររវាងភូមិភាគបូព៌ា និងភូមិភាគនិរតីដែលជាការវាយប្រយុទ្ធគ្នា "ដណ្ដើមប្រទេស"[50]។ ប៊ុត រុំ (2-TCW-1054) ជាទាហានម្នាក់នៅក្នុងកងកាំភ្លើងធំនៃកងពល ៧០៣ ហើយគាត់បានផ្ដល់ភស្ដុតាងទាក់ទងនឹងជម្លោះផ្ទៃក្នុងនៅត្រឹមខែ មេសា ឆ្នាំ ១៩៧៦ ជាពិសេសគាត់ត្រូវបានគេបញ្ជាឲ្យទៅការពារប្រជាជនទប់ទល់នឹងការវាយប្រហារដែលអាចមានឆាប់ៗពីសំណាក់ សោ ភឹម នៅក្នុងអំឡុងបុណ្យខួបជ័យជម្នះក្នុងឆ្នាំ ១៩៧៦[51]។ ខាន់ ប៉ត (2-TCW-1055) ជាទាហានម្នាក់ក្នុងកងពល ៧០៣ ដែលបានផ្ដល់ការពិពណ៌នាអំពីការឈ្លានពានរបស់វៀតណាមចូលក្នុងទឹកដីកម្ពុជានៅត្រឹមឆ្នាំ ១៩៧៦ និងអំពីការប៉ុនប៉ងបង្ក្រាបកម្លាំងបះបោរដែលបានចូលរួមជាមួយនឹងវៀតណាម[52]។ ទុយ ប៉េង ឈន (2-TCW-1056) ជាប្រធានកងកុមារនៅក្នុងកងពលធំ ៧០៣ ហើយអាចផ្ដល់ភស្ដុតាងអំពីអំពើក្បត់របស់ ចាន់ ចក្រី និងការចាប់ខ្លួនជាបន្ដបន្ទាប់ ក៏ដូចជាភស្ដុតាងជាទូទៅអំពីជើងឯក[53]។ ជាចុងក្រោយ ស ខេង (2-TCW-1057) ជាមេដឹកនាំកងវរសេនាតូចនៅក្នុងក្រុមបះបោរនៃភូមិភាគបូព៌ា ដែលបានចូលរួមក្នុងកិច្ចប្រជុំជាមួយ ហេង សំរិន (2-TCW-831), ហ៊ុន សែន (2-TCW-1001) និង ជា ស៊ីម នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៧៧ ដែលតាមការអះអាងថា បានផ្ដោតលើការកម្ទេចយុទ្ធជនភូមិភាគបូព៌ា និងរត់គេចខ្លួនទៅប្រទេសវៀតណាម[54]។ ដូច្នេះ មេធាវីការពារក្ដីអះអាងថា គាត់ទំនងជាអាចផ្ដល់ភស្ដុតាងអំពីការបះបោរ និងការដាក់ពន្ធនាគារកម្មាភិបាលភូមិភាគបូព៌ានាពេលក្រោយមក រួមទាំងនៅមន្ទីរ ស-២១ ផងដែរ[55]។

១៩. មេធាវីការពារក្ដី នួន ជា ស្នើសុំឲ្យស្ដាប់សក្ខីកម្ម ឈុំ ភួត (2-TCW-1058) ទាក់ទងនឹងជម្លោះផ្ទៃក្នុងនៅព្រំដែនថៃ ពោលគឺក្នុងភូមិភាគពាយ័ព្យ[56]។ សាក្សីនេះ គឺជាកងទ័ពនៅក្នុងអំឡុងរបបកម្ពុជា

---

[50] សំណើទីប្រាំ កថាខណ្ឌ ១៨។

[51] សំណើទីប្រាំ កថាខណ្ឌ ១៩។

[52] សំណើទីប្រាំ កថាខណ្ឌ ២១។

[53] សំណើទីប្រាំ កថាខណ្ឌ ២២-២៣។

[54] សំណើទីប្រាំ កថាខណ្ឌ ២៤។

[55] សំណើទីប្រាំ កថាខណ្ឌ ២៥។

[56] សំណើទីប្រាំ កថាខណ្ឌ ២៧-២៨។

ប្រជាធិបតេយ្យ និងឈរជើងនៅព្រំដែនថៃ-កម្ពុជាប្រជាធិបតេយ្យ។ គាត់លើកឡើងថា នៅឆ្នាំ ១៩៧៧ មេដឹកនាំនៅក្នុងកងរបស់គាត់ម្នាក់ឈ្មោះ យឿន យ៉ុង ដែលដឹកនាំក្រុមបះបោរប្រឆាំងនឹងខ្មែរក្រហម បានឱ្យប្រជាជនរត់គេចទៅប្រទេសថៃ[57]។ លើសពីនេះទៅទៀត មេធាវីការពារក្តីស្នើសុំឱ្យស្តាប់សក្ខីកម្ម តុប ឡូញ (2-TCW-1059) ដែលអាចផ្តល់ភស្តុតាងអំពីកងពិសេសដែលចាត់តាំងឡើងដើម្បីតាមដានកម្មករក្នុងការកំណត់អត្តសញ្ញាណជនក្បត់សំខាន់ៗ។ យោងតាមមេធាវីការពារក្តី ដំណើរការតាមដានដែលពិណ៌នាដោយសាក្សីរូបនេះ ផ្តល់ភស្តុតាងគាំទ្រដល់ការអះអាងរបស់មេធាវីការពារក្តីដែលថា ការចាប់ខ្លួនភាគច្រើនដែលបានធ្វើឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺធ្វើឡើងតាមទំនើងចិត្ត[58]។

២០. សាក្សី ២ រូបចុងក្រោយដែលស្នើឡើងដោយមេធាវីការពារក្តី នួន ជា មានឈ្មោះ ទេស អុល (2-TCW-1060) និង ស្រេង ធី (2-TCW-1061) នឹងផ្តល់សក្ខីកម្មពីការដោះលែងអ្នកទោសមន្ទីរសន្តិសុខ ស-២១។ ទេស អុល (2-TCW-1060) ជាពេទ្យនៅក្នុងកងពល ៣១០ នៅក្រោមការគ្រប់គ្រងរបស់ អឿន។ គាត់ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១ ចំនួនពីរថ្ងៃ មុនពេលត្រូវបានដោះលែង[59]។ ស្រេង ធី (2-TCW-1061) ជាទាហានកងពល ៥០២ ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ដោយគាត់ត្រូវបានជាប់ឃុំរយៈពេលពីរខែកន្លះ មុនពេលដែលគាត់ត្រូវបានបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង។ គាត់បានលើកឡើងថា គាត់ត្រូវបានដោះលែងរួមជាមួយមនុស្សប្រហែល ៥០ នាក់ផ្សេងទៀត[60]។

២១. មេធាវីការពារក្តី នួន ជា លើកឡើងថា សំណើនេះបានដាក់ទាន់ពេលវេលា ពីព្រោះកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលពាក់ព័ន្ធ ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦។ ទោះជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីអះអាងថា ភស្តុតាងនេះទាក់ទងទៅនឹងសម្ភារៈដែលបានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះ និងមានខ្លឹមសារដោះបន្ទុក ដូច្នេះហើយ វាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត[61]។

---

[57] សំណើទីប្រាំ កថាខណ្ឌ ២៧។

[58] សំណើទីប្រាំ កថាខណ្ឌ ២៩-៣០។

[59] សំណើទីប្រាំ កថាខណ្ឌ ៣២។

[60] សំណើទីប្រាំ កថាខណ្ឌ ៣៤-៣៥។

[61] សំណើទីប្រាំ កថាខណ្ឌ ៣៩-៤០។

### ៣.២. ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើរបស់ នួន ជា

២២. សហមេធាវីនាំមុខឆ្លើយតបថា សំណើទីមួយពុំផ្តល់សំអាងហេតុ ថាតើភស្តុតាងបន្ថែមដែលបានស្នើសុំនោះ មានទំនាក់ទំនងទៅនឹងការចោទប្រកាន់លើអង្គហេតុដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ សម្រាប់មន្ទីរសន្តិសុខ និងការបោសសំអាតផ្ទៃក្នុង ដោយរបៀបណានោះទេ[62]។ ហេតុនេះ សហមេធាវីនាំមុខកម្រិតចម្លើយតបរបស់ខ្លួនត្រឹមតែការដាក់សំណើមិនបានទាន់ពេលវេលាប៉ុណ្ណោះ ដោយសង្កត់ធ្ងន់ថា ភាគីអាចរកចម្លើយរបស់សាក្សីទាំង ៦ រូបដែលបានស្នើសុំទាំងនេះបាន មុនពេលចាប់ផ្តើមដំណើរការសំណុំរឿង ០០២/០២ ហើយថា មេធាវីការពារក្តីធ្លាប់បានប្រើប្រាស់ចម្លើយមួយចំនួនក្នុងចំណោមចម្លើយទាំងនេះ ដើម្បីសួរដេញដោលសាក្សីក្នុងតុលាការរួចហើយ[63]។ ចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុងវិញ សហមេធាវីនាំមុខកត់សម្គាល់ថា មេធាវីការពារក្តី នួន ជា មិនបានពន្យល់ ថាតើខ្លួនមានបានស្នើសុំបំពេញកិច្ចស៊ើបសួរនេះនៅដំណាក់កាលមុនការជំនុំជម្រះដែរ ឬ ទេ ឬ ហេតុអ្វីបានជាសំណើសុំនេះទើបតែផុសឡើង នៅក្នុងពេលដែលកិច្ចដំណើរការនីតិវិធីជំនុំជម្រះបានប្រព្រឹត្តទៅជាងពាក់កណ្តាលទៅហើយនោះ។ ជាងនេះទៀត សហមេធាវីនាំមុខលើកឡើងថា សំណើទីមួយពិតជាបានពន្យល់ពីរបៀបដែលការស៊ើបអង្កេតអាចនឹងនាំឱ្យមានភស្តុតាងដោះបន្ទុក[64]។ សហមេធាវីនាំមុខបានស្នើសុំឱ្យអង្គជំនុំជម្រះសុំការបញ្ជាក់បំភ្លឺពីមេធាវីការពារក្តី ឬ បដិសេធសំណើទីមួយជាបន្ទាន់[65]។

២៣. នៅក្នុងចម្លើយតបរួមទៅនឹងសំណើទីពីរ និង ទីបី សហមេធាវីនាំមុខលើកឡើងថា នៅក្នុងសំណុំរឿង ០០២/០២ វិសាលភាពនៃការចោទប្រកាន់លើអង្គហេតុពាក់ព័ន្ធនឹងការបោសសម្អាតផ្ទៃក្នុង ត្រូវបានកម្រិតត្រឹមតែបញ្ហាគោលនយោបាយនៅក្នុង "ភូមិភាគឧត្តរចាស់ និងភូមិភាគឧត្តរថ្មី និង ភូមិភាគបូព៌ា" តែប៉ុណ្ណោះ[66]។ ហេតុនេះ ឧក្រិដ្ឋកម្ម ឬគោលនយោបាយនៃការបោសសម្អាតផ្ទៃក្នុងនៅក្នុងភូមិភាគពាយ័ព្យ និងភូមិភាគឦសាន ត្រូវបានដកចេញ លើកលែងតែក្នុងករណីដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[67]។ ជាពិសេស សហ-

---

[62] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីមួយ កថាខណ្ឌ ១៤, ១៧។

[63] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីមួយ កថាខណ្ឌ ១៥, ១៧។

[64] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីមួយ កថាខណ្ឌ ១៨។

[65] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីមួយ កថាខណ្ឌ ២០។

[66] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីពីរ និង ទីបី កថាខណ្ឌ ៨, ១៥។

[67] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីពីរ និង ទីបី កថាខណ្ឌ ៨។

មេធាវីនាំមុខលើកឡើងថា សំណើទីបីមិនបានបង្ហាញ ថាតើសាក្សីបន្ថែមដែលបានស្នើសុំនោះ ជាប់ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខចំនួន ៣ ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ឬ គោលនយោបាយនៃការបោសសម្អាតផ្ទៃក្នុងនៅក្នុងភូមិភាគឧត្តរ និង ភូមិភាគបូព៌ា ដោយរបៀបណានោះទេ[68]។ ពួកគេក៏បានកត់សម្គាល់ផងដែរថា ម៉ី សារឿន (2-TCCP-1040) គឺជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០២ ហេតុនេះ ប្រសិនបើអង្គជំនុំជម្រះសម្រេចកោះហៅគាត់មកផ្តល់សក្ខីកម្ម គួរតែកោះហៅគាត់ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី[69]។

២៤. ជាពិសេស ទាក់ទងនឹងសំណើទីពីរ សហមេធាវីនាំមុខលើកឡើងថា សំណើសុំឱ្យមេធាវីការពារក្តីស្តាប់ចម្លើយ គន់ គីម (2-TCW-1035) និង កា ដេវ (2-TCW-998) នោះ មិនមានមូលដ្ឋាននៅក្នុងវិធានផ្ទៃក្នុង ក្នុងក្របខណ្ឌនីតិវិធីរបស់ អ.វ.ត.ក. និង/ឬ នីតិវិធីព្រហ្មទណ្ឌកម្ពុជានោះទេ។ ហេតុនេះ ពួកគេលើកឡើងថា សំណើនេះគួរត្រូវច្រានចោល[70]។ សហមេធាវីនាំមុខគោរពទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះថាតើ គួរ ឬ មិនគួរស្តាប់សក្ខីកម្មសាក្សីទាំងពីររូបនេះ ដែលពួកគេនៅតែរក្សាសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា សក្ខីកម្មរបស់សាក្សីទាំងពីររូបនេះមានវិសាលភាពតិចតួចទាក់ទងនឹងការបោសសម្អាតផ្ទៃក្នុងសម្រាប់សំណុំរឿង ០០២/០២[71]។

២៥. ក្នុងការឆ្លើយតបទៅនឹងសំណើទីបួន សហមេធាវីនាំមុខលើកឡើងថា លី ហ៊ា (2-TCW-956) បានទទួលមរណភាពហើយ ហេតុនេះសំណើសុំពន្លឿនការស្តាប់សក្ខីកម្មរបស់គាត់គួរទុកជាមោឃៈ[72]។ ទាក់ទងនឹងបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស. វិញ សហមេធាវីនាំមុខលើកឡើងថា វាជាសមិទ្ធផលការងាររបស់ក្រុមអ្នកស៊ើបអង្កេត ដែលមិនមានបំណងយកមកប្រើប្រាស់ជាភស្តុតាងទេ គ្រាន់តែជាការយោងទៅឯកសារមូលដ្ឋាននានាដែលបានទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ រួចហើយ[73]។ សហមេធាវីនាំមុខស្នើសុំដល់អង្គជំនុំជម្រះមេត្តា

[68] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីពីរ និង ទីបី កថាខណ្ឌ ១៧។

[69] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីពីរ និង ទីបី កថាខណ្ឌ ១៨-១៩។

[70] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីពីរ និង ទីបី កថាខណ្ឌ ២០-២១។

[71] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីពីរ និង ទីបី កថាខណ្ឌ ២២។

[72] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីបួន កថាខណ្ឌ ១០, ២២។

[73] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីបួន កថាខណ្ឌ ១១-១៨។ *សូមមើលផងដែរ* សេចក្តីសម្រេចស្តីពីការទទួលយកបញ្ជីថ្មីនៃឈ្មោះអ្នកជាប់ឃុំដែលការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្កើតឡើង ឯកសារ E393 ចុះថ្ងៃទី សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា សុំស្តាប់សក្ខីកម្មសាក្សីបន្ថែមអនុលោមតាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុង (ឯកសារ E391, E392, E395,E412 និង E426) (សំអាងហេតុពេញលេញ)/សម្ងាត់/ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៧១៥/៣១

ពិចារណាចំពោះសេចក្តីសន្និដ្ឋានរបស់ពួកគេ ទាក់ទងនឹងការកោះហៅ ហ៊ិន សុធានី (2-TCW-1042) និង Hiroto FUJIWARA[74]។

## ៤. ច្បាប់ជាធរមាន

២៦. អនុលោមតាមវិធាន ៩១ (១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះត្រូវស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និង អ្នកជំនាញដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍[75]។

២៧. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនីតិវិធីនៃការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកនូវភស្តុតាងទាំងឡាយណា ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភស្តុតាងទាំងអស់នោះបំពេញនូវបទដ្ឋាន*ការបញ្ជាក់បឋម*នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងថ្មីស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏តម្រូវផងដែរថា ភាគីដែលស្នើសុំឱ្យទទួលយកភស្តុតាងថ្មីត្រូវបញ្ជាក់ពីមូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថាភស្តុតាងដែលខ្លួនបានស្នើសុំនោះ មិនអាចរកបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះ ឬ មិនអាចត្រូវបានរកឃើញ ទោះបីជាបានយកចិត្តទុកដាក់សមស្របហើយក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងនានាដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមទាំងនៅក្នុងករណី ដែលភស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងក្នុងករណីដែលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា និងករណីដែលឯកសារ

---

០៥ ខែ មេសា ឆ្នាំ ២០១៦។ ការទទួលយកឯកសារនានាដែលជាមូលដ្ឋាននៃបញ្ជីឈ្មោះអ្នកជាប់ឃុំនៅមន្ទីរ ស-២១ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) បានបង្កើតឡើង ឯកសារ E393/1 ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦។

[74] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីបួន កថាខណ្ឌ ២២។

[75] វិធាន ៩១(១) នៃវិធានផ្ទៃក្នុង។

ដែលបានស្នើសុំនេះ គឺជាភ័ស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌[76]។

២៨. ការពិចារណាឡើងវិញមិនមែនជាផ្នែកនៃក្របខណ្ឌច្បាប់នៅ អ.វ.ត.ក. នោះទេ[77]។ អង្គជំនុំជម្រះនឹងពិចារណាតែទៅលើសំណើថ្មីដែល "សំណើថ្មីនោះមានភ័ស្តុតាងថ្មី ឬ កាលៈទេសៈថ្មី" ប៉ុណ្ណោះ[78]។

---

[76] សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំឱ្យទទួលយកឯកសារចំនួន ២៩ ទាក់ទងនឹងសក្ខីកម្មរបស់អ្នកជំនាញ 2-TCE-95 ឯកសារ E367/8 ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៦ កថាខណ្ឌ ១១។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និង ខៀវ សំផន (E236/4/1, E265, E271, E276, E276/1) ឯកសារ E276/2 ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ២។

[77] សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យពិចារណាឡើងវិញក្នុងការទទួលយកអត្ថបទដកស្រង់មួយ និង ទទួលយកអត្ថបទដកស្រង់ពីរបន្ថែមទៀតពីរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស "រយៈពេល ៣០ ឆ្នាំនៃការកាន់តំណែងរបស់ ហ៊ុន សែន" ឯកសារ E347/4 ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ៧ ("សេចក្តីសម្រេចលើការពិចារណាឡើងវិញ")។ សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំកោះហៅសាក្សី ប្រាក់ ខន (2-TCW-931) ជាថ្មី ឯកសារ E409/3 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦ កថាខណ្ឌ ៦។

[78] សេចក្តីសម្រេចលើការពិចារណាឡើងវិញ កថាខណ្ឌ ៧។ សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំកោះហៅសាក្សី ប្រាក់ ខន (2-TCW-931) ជាថ្មី ឯកសារ E409/3 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦ កថាខណ្ឌ ៦។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ ខៀវ សំផន សុំឱ្យពិចារណាឡើងវិញលើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២" ឯកសារ E314/5/3 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ២។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចទាក់ទងនឹងការទទួលយកសារទូរលេខតាមផ្លូវការទូតរបស់សហរដ្ឋអាមេរិក ដែលទើបរកបានថ្មីៗ (ឯកសារ E282/2/1) និងចម្លើយតបរបស់ ខៀវ សំផន (ឯកសារ E282/2/1/1) ឯកសារ E282/2/1/2 ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៣។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "សេចក្តីសម្រេចលើសំណើបន្ទាន់របស់ ខៀវ សំផន ដែលសុំការបំភ្លឺអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃចម្លើយ និង ប្រតិចារឹក (E299/1) ឯកសារ E299/2 ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៥។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងសំណើសុំបន្ថែម ឯកសារ E238/11/1 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ ៧-៨។ និង អនុស្សរ-ណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យអង្គជំនុំជម្រះសាលា-ដំបូងកុំផ្តល់កំណត់ហេតុនៃការស្តាប់ចម្លើយមុនៗរបស់សាក្សីទាក់ទងនឹងទួលពោធិ៍ជ្រៃ ដល់សាក្សីនៅមុនការផ្តល់សក្ខីកម្ម (ឯក-សារ E292/2) ឯកសារ E292/2/1 ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៤។

២៩. អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិផ្តួចផ្តើមឱ្យមានកិច្ចស៊ើបសួរថ្មី ដែលអាចរួមមានការស្តាប់ចម្លើយសាក្សី ឬដឹកនាំការឆែកឆេរ នៅពេលចាំបាច់[79]។ ភាពចាំបាច់នេះត្រូវតែសំអាងលើផលប្រយោជន៍នៃយុត្តិធម៌។ ដូចគ្នាដែរ ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានគេយល់ដឹងបាននៅក្នុងបរិបទនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.ដែលធានានូវសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងឱ្យបានឆាប់រហ័ស ហើយប្រធានសវនាការមានឆន្ទានុសិទ្ធិក្នុងការបដិសេធនូវរាល់នីតិវិធីដែលមិនចាំបាច់ដែលនាំឱ្យមានការពន្យារពេលដល់ការជំនុំជម្រះ[80]។

## ៥. សំអាងហេតុ

៣០. នៅក្នុងសេចក្តីសម្រេចលើសាក្សីបន្ថែម[81] អង្គជំនុំជម្រះបានយល់ព្រមតាមសំណើសុំស្តាប់សក្ខីកម្មសាក្សីចំនួន ៩ រូប និងដើមបណ្តឹងរដ្ឋប្បវេណី ១ រូប ជាពិសេស៖ សែម អំ (2-TCW-1031) និង ស្វ៊ុយ សៅ (2-TCW-1029) ក្នុងសំណើទីមួយ, មាស សឿន (2-TCW-917) ក្នុងសំណើទីពីរ, ជាល ជឿន (2-TCW-960), ហួន ជឿម (2-TCW-1037), ឈន វន (2-TCW-1036) និង ម៉ី សារឿន (2-TCCP-1040) ក្នុងសំណើទីបី, នឹម គីមស្រ៊ាង (2-TCW-854) ក្នុងសំណើទីបួន និង ឡុង វុន (2-TCW-971) និង ទេស អុល (2-TCW-1060) ក្នុងសំណើទីប្រាំ។ អង្គជំនុំជម្រះបានពន្យារពេលចេញសេចក្តីសម្រេចលើ ហេង សំរិន (2-TCW-831), អ៊ុក ប៊ុនឈឿន (2-TCW-951) និង ប៉ុល សារឿន (2-TCW-962) ក្នុងសំណើទីពីរ ព្រមទាំង ហ៊ិន សុធានី (2-TCW-1042)[82] ក្នុងសំណើទីបួន[83]។

---

[79] សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យទទួលយកភស្តុតាងថ្មី, ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោក Rob LEMKIN ឯកសារ E294/1 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣") កថាខណ្ឌ ១១។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៣៩។

[80] សេចក្តីសម្រេចចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១១។ *សូមមើលផងដែរ* ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ អ.វ.ត.ក") មាត្រា ៣៣ថ្មី។ វិធាន ៨៥ នៃវិធានផ្ទៃក្នុង។

[81] *សូមមើល* ជើងទំព័រ ១។

[82] ក្រោយមក អង្គជំនុំជម្រះបានបដិសេធមិនកោះហៅ ហេង សំរិន (2-TCW-831) អ៊ុក ប៊ុនឈឿន (2-TCW-951) និង ប៉ុល សារឿន (2-TCW-962) និងបានទទួលយកសំណើសុំកោះហៅ ហ៊ិន សុធានី (2-TCW-1042)។ *សូមមើល* នៅក្នុងបញ្ជីឈ្មោះ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា សុំស្តាប់សក្ខីកម្មសាក្សីបន្ថែមអនុលោមតាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុង (ឯកសារ E391, E392, E395,E412 និង E426) (សំអាងហេតុពេញលេញ)/សម្ងាត់/ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៧

៣១. អង្គជំនុំជម្រះសូមរម្លឹកឡើងវិញថា អង្គជំនុំជម្រះមិនអាចកោះហៅសាក្សី ៤ រូប ដែលបានស្នើសុំទេ ដោយសារពួកគាត់បានទទួលមរណភាពរួចហើយរួមមាន៖ទាត់ ធឿន (2-TCW-829) និង អន សុភាព (2-TCW-1041) ក្នុងសំណើទីបី និង ម៉ម ណៃ (2-TCW-864) និង លី ហ៊ាវ (2-TCW-956) ក្នុងសំណើទីបួន។ ប្រការនេះធ្វើឱ្យសំណើសុំពាក់ព័ន្ធនឹងសាក្សីទាំងនេះត្រូវទុកជាមោឃៈ។ អង្គជំនុំជម្រះបានបដិសេធផ្នែកផ្សេងទៀតនៃសំណើសុំ ដោយកត់សម្គាល់ថា អង្គជំនុំជម្រះបានស្នើសុំព័ត៌មានពី Walter HEYNOWSKI (2-TCW-946) ជំនួសឱ្យការស្តាប់សក្ខីកម្មរូបគាត់[84]។

៣២. ជាបញ្ហាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា សំណើទីពីរ ទីបី និង ទីបួន រួមបញ្ចូលសំណើសុំពន្លឿនការស្តាប់សក្ខីកម្មសាក្សីសរុបចំនួន ១១ រូប ដែលមេធាវីការពារក្តីធ្លាប់បានស្នើសុំនៅក្នុងសំណើមុនៗ។ សំអាងហេតុទាក់ទងនឹងសាក្សីចំនួន ៨ រូប ក្នុងចំណោមសាក្សីទាំងនោះនឹងត្រូវបញ្ជាក់ជូននៅក្នុងសេចក្តីសម្រេចលើសាក្សីស្ថាពរនៅក្នុងសំណុំរឿង ០០២/០២ របស់អង្គជំនុំជម្រះ។ សាក្សីពាក់ព័ន្ធដែលបានស្នើសុំ រួមមាន ហេង សំរិន (2-TCW-831), អ៊ុក ប៊ុនឈឿន (2-TCW-951), ប៉ែន សុវណ្ណ (2-TCW-952), ប៉ុល សារឿន (2-TCW-962) ក្នុងសំណើទីពីរ, Walter HEYNOWSKI (2-TCW-946), ឆាំង យុ (2-TCW-870), យិន នាន (2-TCW-963) និង ជ័យ សុភារ៉ា (2-TCW-81) ក្នុងសំណើទីបួនរបស់ នួន ជា។ ទន្ទឹមនឹងនោះដែរ សំអាងហេតុសម្រាប់ការមិនកោះហៅ Robert LEMKIN (2-TCW-877), ចាន់ សាវុត (2-TCW-959) និង អ៊ិន ធឿន (2-TCW-961) ដែលបានស្នើសុំពន្លឿនការកោះហៅនៅក្នុងសំណើទីបី នឹងត្រូវបញ្ជាក់ជូននៅក្នុងសេចក្តីសម្រេចនេះ។

---

ចុងក្រោយនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញ សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E454 ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦។ អ៊ីមែលពីអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគីចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៦។

[83] សេចក្តីសម្រេចលើសាក្សីបន្ថែម។ អង្គជំនុំជម្រះសូមរម្លឹកឡើងវិញថា អង្គជំនុំជម្រះធ្លាប់បានជ្រើសរើស មាស សឿន (2-TCW-917) និង ទាត់ ធឿន (2-TCW-829) មកផ្តល់សក្ខីកម្មក្នុងអំឡុងការជំនុំជម្រះលើអង្គហេតុស្តីពីមន្ទីរសន្តិសុខ និង ការបោសសម្អាតផ្ទៃក្នុង។ ទោះជាយ៉ាងណាក្តី សាក្សី ទាត់ ធឿន បានទទួលមរណភាពមុនពេលកំណត់មកផ្តល់សក្ខីកម្ម។ *សូមមើល* អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគី ពាក់ព័ន្ធនឹង “ការបោសសម្អាតផ្ទៃក្នុង៖ បញ្ជីឈ្មោះសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ” ឯកសារ E408/6.1 ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ (សម្ងាត់)។ អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគី ពាក់ព័ន្ធនឹង “ការកំណត់កាលបរិច្ឆេទសវនាការ” ឯកសារ E408/6.2 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ (ជូនដំណឹងដល់ភាគីអំពីមរណភាពរបស់ 2-TCW-829) (សម្ងាត់)។

[84] សេចក្តីសម្រេចលើសាក្សីបន្ថែម។

៣៣. នៅក្នុងសំណើទីពីរ មានការស្នើសុំឱ្យពិចារណាឡើងវិញលើសេចក្ដីសម្រេចមិនកោះហៅ ហ៊ុន សែន (2-TCW-1001) និង កា ផេវ (2-TCW-998)[85]។ អង្គជំនុំជម្រះសូមរម្លឹកឡើងវិញថា នៅក្នុងក្របខណ្ឌនីតិវិធីនៅ អ.វ.ត.ក. អង្គជំនុំជម្រះអាចចាត់ទុកសំណើមួយ ជាសំណើថ្មីបាន នៅពេលសំណើសុំថ្មីនោះបានដាក់ និងបានធ្វើយុត្តិកម្ម ដោយបង្ហាញភ័ស្តុតាងថ្មី ឬ កាលៈទេសៈថ្មីតែប៉ុណ្ណោះ[86]។ ទោះបីជាមេធាវីការពារក្ដីទទួលស្គាល់ថា សំណើរបស់ពួកគេមិនស្របទៅនឹងលក្ខណៈវិនិច្ឆ័យទាំងនេះក៏ដោយ ក៏ពួកគេលើកឡើងថា អង្គជំនុំជម្រះគួរអនុវត្ត "លក្ខណៈវិនិច្ឆ័យទូលាយ" ដែលអនុញ្ញាតឱ្យមានការពិចារណាឡើងវិញនៅក្នុងកាលទេសៈទាំងនេះ[87]។ អង្គជំនុំជម្រះសូមរម្លឹកឡើងវិញថា អង្គជំនុំជម្រះបានពិចារណារួចហើយទៅលើសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីដែលយោងទៅដល់លក្ខណៈវិនិច្ឆ័យដែលបានអនុវត្តដោយតុលាការ *មិនអចិន្ត្រៃយ៍* និង បានសម្រេចលើបញ្ហានេះរួចហើយ[88]។ ដោយមិនមានភ័ស្តុតាងថ្មី ឬ កាលៈទេសៈថ្មី អង្គជំនុំជម្រះនឹងមិនចាត់ទុកថាសំណើរបស់មេធាវីការពារក្ដីជាសំណើថ្មីនោះទេ។ ហេតុនេះ អង្គជំនុំជម្រះបដិសេធសំណើសុំឱ្យពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់ខ្លួនដែលសម្រេចមិនស្ដាប់សក្ខីកម្មរបស់ ហ៊ុន សែន (2-TCW-1001) និង កា ផេវ (2-TCW-998)[89] និងសំណើពាក់ព័ន្ធនឹងការស្ដាប់ចម្លើយរបស់ កា ផេវ (2-TCW-998) អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង។

៣៤. សម្រាប់សាក្សីផ្សេងទៀតដែលបានស្នើសុំ អង្គជំនុំជម្រះសន្និដ្ឋានថា មានតែសំណើទីបួនមួយគត់ដែលបានដាក់ទាន់ពេលវេលា។ សំណើសុំកោះហៅ ហ៊ុន សុធានី (2-TCW-1042), Hiroto FUJIWARA (2-TCW-1043) និង នួន ម៉ាលី (2-TCW-1044) កើតចេញមកពីឯកសារដែលភាគីអាចរកបាននៅខែ មេសា ឆ្នាំ ២០១៦[90] មួយរយៈពេលខ្លីមុនពេល នួន ជា ដាក់សំណើទីបួននៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦។ ផ្ទុយទៅវិញ ចម្លើយរបស់សាក្សីដែលបានស្នើសុំនៅក្នុងសំណើទី

---

[85] សំណើទីពីរ កថាខណ្ឌ ២, ៨, ៣៧។

[86] *សូមមើល* ជើងទំព័រ ៧៩។

[87] សំណើទីពីរ កថាខណ្ឌ ១៥-១៦។

[88] សេចក្ដីសម្រេចលើការពិចារណាឡើងវិញ កថាខណ្ឌ ៧។

[89] *សូមមើល* សេចក្ដីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យពន្លឿនការកោះហៅសាក្សី ២ រូប ដែលបានស្នើសុំរួចហើយ និងសុំឱ្យកោះហៅសាក្សីបន្ថែមចំនួន ៤ រូប នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង 00២/0២ ពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិចាម និង លើសំណើរបស់សហព្រះរាជអាជ្ញាជាតិសុំឱ្យទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរជំនួសឱ្យការចូលបង្ហាញខ្លួនដោយផ្ទាល់នៅតុលាការ ឯកសារ E370/4 ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៦ (សម្ងាត់)។

[90] សំណើទីបួន កថាខណ្ឌ ៣៦។

មួយ អាចរកបានមុនពេលចាប់ផ្ដើមជំនុំជម្រះលើសំណុំរឿង 00២/0២ ហើយសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីដែលថា តម្រូវការក្នុងការស្ដាប់សក្ខីកម្មសាក្សីទាំងនេះ "មានលក្ខណៈដាច់ខាត និងជាក់ស្ដែង" ក្នុងអំឡុងពេលជំនុំជម្រះ មិនគួរឱ្យជឿជាក់បានទេ[91]។ ទាក់ទងនឹងសំណើតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ដែលសុំស្វែងរកអ្នកផ្ដាច់ខ្លួន ដោយផ្អែកលើសៀវភៅ *The Pol Pot Regime (របប ប៉ុល ពត)* របស់ Ben Kiernan វិញ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សៀវភៅនេះបានបោះពុម្ពលើកទីមួយនៅឆ្នាំ ១៩៩៦ និងបានដាក់ចូលទៅក្នុងសំណុំរឿងជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ហេតុនេះ សំណើសុំនេះមិនបានដាក់ទាន់ពេលវេលាទេ។

៣៥. ទាក់ទងនឹងសំណើទីពីរ សេចក្ដីសន្និដ្ឋានដែលថាមេធាវីការពារក្ដី "រង់ចាំការបញ្ជាក់លម្អិត" អំពី គន់ គីម (2-TCW-1035) ក្នុងអំឡុងពេលកិច្ចដំណើរការជំនុំជម្រះថ្ងៃទី 0៩ ខែ មីនា ឆ្នាំ ២០១៦[92] មិនបានបង្ហាញពីការបំពេញទៅតាមលក្ខណៈវិនិច្ឆ័យ នៃការយកចិត្តទុកដាក់សមស្របនោះទេ។ ព័ត៌មានដែលមេធាវីការពារក្ដីបានស្នើសុំដើម្បី "បញ្ជាក់" នៅក្នុងតុលាការ កើតចេញមកពីកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីមួយចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២00៨ និងបានបញ្ចូលទៅក្នុងសំណុំរឿងនៅមុនពេលចាប់ផ្ដើមជំនុំជម្រះក្នុងសំណុំរឿង 00២/0២ មកម្ល៉េះ[93]។ ស្រដៀងគ្នាដែរសម្រាប់សាក្សីដែលបានស្នើសុំនៅក្នុងសំណើទីបី កំណត់ហេតុនៃការស្ដាប់ចម្លើយ សាម៉ី សាវើង (2-TCW-1038) និង ឈួម សាវ៉ុន (2-TCW-1039) មានតាំងពីឆ្នាំ ២០១៣ និង ២០១៤ ហើយមេធាវីការពារក្ដីបានចូលពិនិត្យមើលឯកសារទាំងនេះតាំងពីឆ្នាំ ២០១៥ មកម្ល៉េះ[94]។ ការសម្រេចចិត្តជាយុទ្ធសាស្ត្រដោយភាន់ច្រឡំរបស់មេធាវីការពារក្ដី ក្នុងការរង់ចាំការបញ្ចប់ការជំនុំជម្រះលើវគ្គសវនាការស្ដីពីមន្ទីរសន្តិសុខ និង ការបោសសម្អាតផ្ទៃក្នុង មុនពេលសម្រេចថាតើ គួរ ឬមិនគួរស្នើសុំកោះហៅសាក្សី[95] បានធ្វើឱ្យសំណើនេះក្លាយជាសំណើដាក់មិនទាន់ពេលវេលា។ ចុងក្រោយកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពាក់ព័ន្ធនឹងសាក្សីដែលបានស្នើសុំនៅក្នុងសំណើទីប្រាំរបស់ នួន ជា ចុះកាលបរិច្ឆេទចាប់ពីឆ្នាំ ២000 ដល់ ២00១ ហើយឯកសារទាំងនេះមានជា

---

[91] សំណើទីមួយ កថាខណ្ឌ ២៤។

[92] សំណើទីពីរ កថាខណ្ឌ ៣១។

[93] *សូមមើល* កំណត់ហេតុស្ដាប់ចម្លើយសាក្សី សឡេះ អះម៉ាត់ ឯកសារ E3/5209 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២00៨ ទំព័រ ៥។

[94] *សូមមើល* សំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំឱ្យទទួលយកចម្លើយសាក្សីចំនួន ៦ និងឧបសម្ព័ន្ធមួយដែលពាក់ព័ន្ធនឹងសំណុំរឿង 00២/0២ ឯកសារ E319/30 ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥ កថាខណ្ឌ ១២-១៣ (សម្ងាត់)។

[95] សំណើទីបី កថាខណ្ឌ ២៩-៣០, ៣៥, ៤០។

សាធារណៈតាំងពីមុនពេលចាប់ផ្តើមជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ម៉្លេះ។ សេចក្តីសន្និដ្ឋានដែលថា សំណើនេះដាក់ទាន់ពេលវេលា ដោយសារកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ ក្រោយពេលមេធាវីការពារក្តី "បានរកឃើញ"[96] អាចអនុវត្តបានចំពោះតែសាក្សី ៥ រូប ប៉ុណ្ណោះ ក្នុងចំណោមសាក្សីដែលបានស្នើសុំ[97] ហើយភាពយឺតយ៉ាវក្នុងការ "រកឃើញ" កិច្ចសម្ភាសន៍ដែលចុះកាលបរិច្ឆេទចាប់ពីឆ្នាំ ២០០០ ដល់ ឆ្នាំ ២០០១ ទាំងនេះ បង្ហាញថា មេធាវីការពារក្តីមិនបានបំពេញការងារដោយយកចិត្តទុកដាក់សមស្របនោះទេ។ ចម្លើយរបស់សាក្សីចំនួន ៦ រូប ផ្សេងទៀតដែលបានស្នើសុំ មាននៅក្នុងសំណុំរឿងរួចហើយ ហើយមេធាវីការពារក្តីមិនបានផ្តល់យុត្តិកម្មអំពីភាពយឺតយ៉ាវក្នុងការដាក់សំណើសុំនេះទេ។ ហេតុនេះ អង្គជំនុំជម្រះសន្និដ្ឋានថា សំណើទីប្រាំរបស់ នួន ជា ពុំបានដាក់ទាន់ពេលវេលាឡើយ។ នាពេលនេះ អង្គជំនុំជម្រះនឹងពិចារណា ថាតើសាក្សីពីសំណើទីបួនដែលមិនបានដាក់ទាន់ពេលវេលា គួរតែត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មដើម្បីជាប្រយោជន៍យុត្តិធម៌ ឬយ៉ាងណា។ ចំណុចនេះតម្រូវឱ្យមានការវាយតម្លៃទៅលើករណីនីមួយៗ ដោយពិចារណាដល់កាលៈទេសៈពាក់ព័ន្ធទាំងអស់។ ក្នុងករណីណាក៏ដោយ គេត្រូវតែបំពេញទៅតាមលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

៣៦. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សាក្សីទាំង ៦ រូប ដែលបានស្នើសុំនៅក្នុងសំណើទីមួយគឺជាសមាជិកកងពល ១ ឬ កងពល ៣១០ ហើយត្រូវបានរំពឹងថានឹងមកផ្តល់សក្ខីកម្មអំពីការប៉ុនប៉ងធ្វើ*រដ្ឋប្រហារ* ជាពិសេសអំពីផែនការដឹកនាំដោយ អឿន។ អង្គជំនុំជម្រះបានស្តាប់សាក្សីជាច្រើននាក់រួចហើយ ព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណី ១ រូប ដែលជាប់ពាក់ព័ន្ធជាមួយនឹងកងពល ៣១០ ហើយដែលបានផ្តល់ភ័ស្តុតាង*ក្នុងនោះ*រួមមានការបោសសម្អាតផ្ទៃក្នុង និងមន្ទីរសន្តិសុខ ស-២១[98]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះយល់ឃើញថា វាជាប្រយោជន៍នៃយុត្តិធម៌ក្នុងការកោះហៅសាក្សីដែលពាក់ព័ន្ធបំផុតដែលបានស្នើឡើងនៅក្នុងសំណើសុំលើកទីមួយដើម្បីផ្តល់ឱកាសឱ្យ នួន ជា បន្ថែមទៀតក្នុង

---

[96] សំណើទីប្រាំរបស់ នួន ជា កថាខណ្ឌ ៣៩-៤០។

[97] ម៉ូវ សុង (2-TCW-1053), ប៊ុត វុំ (2-TCW-1054), ខាន់ ប៉ត (2-TCW-1055), ទុយ ប៉េងឈន (2-TCW-1056) និង គុប ឡូញ (2-TCW-1059)។

[98] *ឧ.* កែវ លឿ (2-TCW-932), ស៊ួយ សៅ (2-TCW-1029), សែម ហឿន (2-TCW-943), ហ៊ឹម ហ៊ន ហៅ រឿម (2-TCW-901) និង ឆែ ហៀប (2-TCCP-275)។

ការបង្កើតទ្រឹស្តីនៃការការពារក្តីរបស់គាត់ ជាពិសេស ពាក់ព័ន្ធនឹងក្រុមផ្ទៃក្នុង[99]។ ក្រោយពីបានពិនិត្យមើលឯកសារពាក់ព័ន្ធនឹងសាក្សីដែលបានស្នើឡើង អង្គជំនុំជម្រះយល់ឃើញថា ចម្លើយរបស់ ស៊្បយ សៅ (2-TCW-1029) និង សេម អំ (2-TCW-1031) រួមមានភ័ស្តុតាងជាប់ពាក់ព័ន្ធបំផុត និងមានលក្ខណៈពិសេស។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំស្តាប់សក្ខីកម្មសាក្សីទាំងពីររូបនេះ។ អង្គជំនុំជម្រះយល់ឃើញថា ភ័ស្តុតាងដែលបានស្នើសុំពីសាក្សីដែលនៅសេសសល់ចំនួន ៤ រូប[100] គឺជាភ័ស្តុតាងច្រំដែល ជាមួយនឹងភ័ស្តុតាងដែលអង្គជំនុំជម្រះបានស្តាប់រួចហើយ លើបញ្ហាទាំងនេះនៅក្នុងសំណុំរឿង ០០២/០២ ពីសាក្សីមួយចំនួន រួមទាំង កែវ លឿ (2-TCW-932),[101] សែម ហឿន (2-TCW-943)[102] និង ឆែ ហៀប (2-TCCP-275)[103]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា លទ្ធភាពក្នុងការទាញយកព័ត៌មានថ្មីៗពីសាក្សីដែលបានស្នើឡើងទាំងនេះ យោងតាមការទទួលស្គាល់របស់មេធាវីការពារក្តី "បានបង្ហាញតិចតួចប៉ុណ្ណោះ" នៅក្នុងចម្លើយរបស់ពួកគេ និងជា "ភ័ស្តុតាងពិសេស" ដែលមេធាវីការពារក្តីអះអាងថា ពួកគេអាចផ្តល់ជូនបាននោះ គឺភាគច្រើនជាការប៉ាន់ស្មាន[104]។ អង្គជំនុំជម្រះយល់ឃើញថា ការស្តាប់សក្ខីកម្មពួកគេ នឹងមិនមែនជាប្រយោជន៍នៃយុត្តិធម៌នោះទេ ដោយកត់សម្គាល់បន្ថែមទៀតអំពីដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធី។ យោងតាមហេតុផលដូចគ្នា អង្គជំនុំជម្រះយល់ឃើញថា ការបំពេញកិច្ចស៊ើបសួរបន្ថែមដើម្បីអាចកំណត់ភ័ស្តុតាងថ្មីៗពាក់ព័ន្ធនឹងក្រុមផ្ទៃក្នុង នឹងមិននាំឱ្យកិច្ចដំណើរការនីតិវិធីដំណើរការទៅបានឆាប់រហ័សនោះឡើយ ជាពិសេសនៅក្នុងដំណាក់កាលជំនុំជម្រះនាពេលនេះ។ ក្រោយពីកត់សម្គាល់ជាពិសេសលើពេលវេលា ដែលបានកន្លងផុតចាប់តាំងពីការបោះពុម្ពផ្សាយសៀវភៅរបស់ Ben Kiernan ការគ្មាន ឬមានព័ត៌មានតិចតួចបំផុតស្តីពីការកំណត់ព័ត៌មានលម្អិតពាក់ព័ន្ធនឹងក្រុមផ្តាច់ខ្លួនដូចបានចោទប្រកាន់ កិច្ចសហប្រតិបត្តិការតិចតួចបំផុតរំពឹងថានឹងទទួល

---

[99] អង្គជំនុំជម្រះនឹងពិចារណាលើផលប៉ះពាល់ទាំងមូលនៃសេចក្តីសន្និដ្ឋានរបស់ នួន ជា នៅក្នុងសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង ០០២/០២។

[100] ថាច សៀក (2-TCW-1030), វង់ វៃ (2-TCW-1032), ខឹម សំហួន (2-TCW-1033) និង សូ រ៉េន (2-TCW-1031)។

[101] *សូមមើល* ប្រតិចារឹក ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥ (កែវ លឿ) ទំព័រ ៦, ៣០-៣២, ៣៤-៣៥។ ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ (កែវ លឿ) ទំព័រ ៨-១០។

[102] *សូមមើល* ប្រតិចារឹក ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ (សែម ហឿន) ទំព័រ ៧៧, ៨២-៨៤។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥ (សែម ហឿន) ទំព័រ ៩, ១៦។

[103] *សូមមើល* ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ (ឆែ ហៀប) ទំព័រ ២៧-២៩។

[104] សំណើសុំលើកទីមួយ កថាខណ្ឌ ២៤-២៥។

បានពី Ben Kiernan ប្រសិនបើមាន[105] ហើយនឹងភ័ស្តុតាងដែលបានស្តាប់រួចហើយស្តីពីអត្ថិភាពនៃក្រុមទាំងនេះក្នុងចំណោម ប.ក.ក. ហេតុដូច្នេះ អង្គជំនុំជម្រះច្រានចោលសំណើសុំរបស់មេធាវីការពារក្តី អនុលោមតាមវិធាន ៨៣ នៃវិធានផ្ទៃក្នុង[106]។

៣៧. ពាក់ព័ន្ធនឹងសំណើទីពីរ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សេចក្តីសន្និដ្ឋានទាក់ទងនឹងភាពពាក់ព័ន្ធរួមនៃសក្ខីកម្មរបស់សាក្សី គន់ គីម (2-TCW-1035) ភាគច្រើនគឺជាការប៉ាន់ស្មាន ដូចបានទទួលស្គាល់ដោយមេធាវីការពារក្តី[107]។ យោងតាមមេធាវីការពារក្តី ហេតុផលចម្បងក្នុងការកោះហៅគាត់ គឺដោយសារគាត់ "អាចផ្តល់ព័ត៌មានមិនអាចរកបានលើការរៀបចំការបះបោរ និងការចូលរួមក្នុងការបង្ក្រាបកម្មាភិបាលនៅភូមិភាគបូព៌ា"[108]។ មេធាវីការពារក្តីសន្និដ្ឋានថា សាក្សី វ៉ាន់ ម៉ាត់ ហៅ សឡេះ អះម៉ាត់ (2-TCW-893) បានបញ្ជាក់ថា គន់ គីម (2-TCW-1035) គឺជាមេដឹកនាំការបះបោរ[109]។ ក៏ប៉ុន្តែ ទោះបីជាអង្គជំនុំជម្រះកត់សម្គាល់ឃើញថា វ៉ាន់ ម៉ាត់ ហៅ សឡេះ អះម៉ាត់ (2-TCW-893) បានអះអាងថា គន់ គីម (2-TCW-1035) បានបញ្ជាកងទ័ពចម្រុះប្រហែល ៤០០ ឬ ៥០០ រហូតដល់ ១០០០ នាក់ដើម្បីតតាំងជាមួយនឹងកងទ័ពរបស់ ប៉ុល ពត ក៏ដោយ ក៏សាក្សីរូបនេះបានបញ្ជាក់បំភ្លឺថា គាត់មិនបានដឹងថា គន់ គីម (2-TCW-1035) កាន់តួនាទីអ្វីនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ នោះទេ ដោយសារគាត់ទើបតែបានស្គាល់ គន់ គីម (2-TCW-1035) មួយខែនៅមុនពេលបះបោរ[110]។ ម្យ៉ាងវិញទៀត វ៉ាន់ ម៉ាត់ ហៅ សឡេះ អះម៉ាត់ (2-

---

[105] អ៊ីមែលពី Ben KIERNAN (2-TCE-89) ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង ឯកសារ E29/509/1 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៦។ អ៊ីមែលពី Ben KIERNAN (2-TCE-89) ផ្ញើជូនអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឯកសារ E29/509 ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥។ *សូមមើលផងដែរ* សក្ខីកម្មរបស់ Benedict KIERNAN ដែលបានស្នើសុំនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E166/1/4 ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ២ ដែលអង្គជំនុំជម្រះចាត់ទុកបុគ្គលនេះថាជា "អ្នកជំនាញខ្វះកិច្ចសហការ"។

[106] សំណើសុំលើកទីមួយ កថាខណ្ឌ ២៦។

[107] សំណើសុំលើកទីពីរ កថាខណ្ឌ ២៨៖ "ចាប់តាំងពី គន់ គីម (សាក្សី ឆ) មិនត្រូវបានស្តាប់ចម្លើយ មេធាវីការពារក្តីគ្រាន់តែទាយស្មានអំពីលទ្ធភាពនៃភាពពាក់ព័ន្ធផ្សេងទៀតចេញពីសក្ខីកម្មរបស់គាត់"។

[108] សំណើសុំលើកទីពីរ កថាខណ្ឌ ២៩។

[109] សំណើសុំលើកទីពីរ កថាខណ្ឌ ២៩។

[110] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ (វ៉ាន់ ម៉ាត់ ហៅ សឡេះ អះម៉ាត់) ទំព័រ ៥៩-៦០, ៦៩។ អង្គជំនុំជម្រះកត់សម្គាល់ថា គន់ គីម (2-TCW-1035) ទំនងជាជនស៊ីវិលនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ *សូមមើល* សំណើសុំលើកទីពីរ កថាខណ្ឌ ៣០៖ "គាត់គឺជាបុគ្គលិកពាណិជ្ជកម្មស្រុកត្បូងឃ្មុំ"។ អង្គហេតុនេះក្រោយមកបានបញ្ជាក់ដោយសាក្សី 2-TCW-1065៖ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា សុំស្តាប់សក្ខីកម្មសាក្សីបន្ថែមអនុលោមតាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុង (ឯកសារ E391, E392, E395,E412 និង E426) (សំអាងហេតុពេញលេញ)/សម្ងាត់/ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៧

TCW-893) បានបញ្ជាក់មិនស៊ីសង្វាក់គ្នាថា គន់ គីម (2-TCW-1035) មិនមានឋានៈខ្ពស់ ឬ ក៏តួនាទីខ្ពស់នៅក្នុងកងទ័ពរំដោះនោះទេ ហើយគាត់បានបញ្ជាកងទ័ពមួយចំនួនតូចតែប៉ុណ្ណោះ[111]។ ចំណុចចុងក្រោយចំពោះការចូលរួមរបស់ គន់ គីម (2-TCW-1035) នៅក្នុងកងទ័ពរំដោះ មុនឆ្នាំ ១៩៧៥ ឬ តួនាទីរបស់គាត់ក្នុងនាមជាមេដឹកនាំការបះបោរនៅពេលនោះ មិនស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងផ្សេងៗទៀតនោះទេ។ នៅក្នុងកាលៈទេសៈបច្ចុប្បន្ន អង្គជំនុំជម្រះយល់ឃើញថា មិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីភាពពាក់ព័ន្ធ*បឋម*នៃសក្ខីកម្មរបស់គាត់ ដែលបានស្នើឡើងនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះច្រានចោលសំណើសុំស្តាប់សក្ខីកម្ម គន់ គីម (2-TCW-1035) ព្រមទាំងសំណើសុំពាក់ព័ន្ធនឹងការស្តាប់ចម្លើយគាត់ អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង។

៣៨. នៅក្នុងសំណើទីប្រាំ មេធាវីការពារក្តី នួន ជា ស្នើសុំឱ្យកោះហៅសាក្សីថ្មីចំនួន ៥ រូប ដែលភាគច្រើនពាក់ព័ន្ធនឹងកងពល ៧០៣ ឲ្យមកផ្តល់សក្ខីកម្មអំពីការបះបោរក្បត់ដោយកម្មាភិបាលភូមិភាគបូព៌ា។ ដូចបានកត់សម្គាល់នៅត្រង់កថាខណ្ឌ ៣៦ នៃសេចក្តីសម្រេចនេះ អង្គជំនុំជម្រះបានស្តាប់ភស្តុតាងជាច្រើនរួចហើយ ទាំងអំពីការបះបោរក្បត់ និងស្ថានភាពនៅក្នុងភូមិភាគបូព៌ា។ ក្រោយពីបានពិនិត្យឡើងវិញលើកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សីដែលបានស្នើឡើងទាំង៥ រូបនេះ អង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងរបស់ពួកគេមានភាពពាក់ព័ន្ធតិចតួចទៅនឹងរឿងក្តីនៃសំណុំរឿង ០០២/០២ ហើយនៅក្នុងវិសាលភាពដែលភស្តុតាងទាំងនេះអាចពាក់ព័ន្ធទូទៅនឹងក្រុមផ្ទៃក្នុងនោះ ភស្តុតាងទាំងនេះមានលក្ខណៈច្រំដែលជាមួយនឹងភស្តុតាងដែលមានរួចហើយនៅក្នុងសំណុំរឿង[112]។ មេធាវីការពារក្តីក៏ស្នើសុំស្តាប់សក្ខីកម្មសាក្សី តុប ឡូញ (2-TCW-1059) ដែលជាសមាជិកម្នាក់ដែរនៅក្នុងកងពល ៧០៣ ដោយបានបញ្ជាក់ថា គាត់អាចផ្តល់ភស្តុតាងពាក់ព័ន្ធនឹងដំណើរការតាមដានអ្នកដែលអាចជាជនក្បត់។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ភស្តុតាងពាក់ព័ន្ធមាននៅក្នុងសំណុំរឿងរួចហើយ ជាពិសេសតាមរយៈសក្ខីកម្មរបស់សាក្សី វ៉ាន់

---

"ខ្ញុំអាចនិយាយបានថា ខ្ញុំបានស្គាល់គាត់នៅក្នុងឆ្នាំ១៩៧៥ ហើយនៅមុនឆ្នាំនោះ គន់ គីម គឺជាជនស៊ីវិល"។ ប្រតិចារឹក ថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ (2-TCW-1065) ទំព័រ ៨៩។

[111] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ (វ៉ាន់ ម៉ាត ហៅ សឡេះ អះម៉ាត់) ទំព័រ ៦០។

[112] *សូមមើល* កថាខណ្ឌ ៣៦។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ (ម៉ី សារឿន) ទំព័រ ១៤-១៦, ៨០។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ (មាស សឿន) ទំព័រ ៣៥-៣៦, ៤០-៦៥, ៨២-៨៥, ៩៥។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៥ (សុះ មីន) ទំព័រ ៣៦, ៣៩។

ម៉ាត់ ហៅ សឡេះ អះម៉ាត់ (2-TCW-893)[113] និងដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សាវឿន (2-TCCP-1040)[114] ហើយពិចារណាឃើញថា វាជាភ័ស្ដុតាងច្រំដែល។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះច្រានចោលសំណើសុំស្ដាប់សក្ខីកម្មសាក្សី ម៉ូវ សុង (2-TCW-1053), ប៉ិត រុំ (2-TCW-1054), ខាន់ ប៉ត (2-TCW-1055), ទុយ ប៉េងឈន (2-TCW-1056), ស ខេង (2-TCW-1057) និង គុប ឡូញ (2-TCW-1059)។ យោងតាមហេតុផលដដែលនេះ អង្គជំនុំជម្រះក៏ច្រានចោលសំណើសុំឱ្យទទួលយកចម្លើយទាំង ៥ ដែលចុះកាលបរិច្ឆេទឆ្នាំ ២០០០ និងឆ្នាំ ២០០១ ធ្វើជាឯកសារភ័ស្ដុតាងផងដែរ។

៣៩. នៅក្នុងសំណើទីបី មេធាវីការពារក្ដី នួន ជា បានស្នើសុំឱ្យកោះហៅសាក្សីថ្មីចំនួន ៤ រូប ដែលជាអតីតកម្មាភិបាលភូមិភាគពាយ័ព្យ ដែលរំពឹងថានឹងមកផ្ដល់សក្ខីកម្មអំពីការបះបោរនៅក្នុងភូមិភាគពាយ័ព្យ និងភាពវឹកវរផ្ទៃក្នុងនៅក្នុង ប.ក.ក.[115]។ ដូចគ្នានេះដែរ នៅក្នុងសំណើទីប្រាំ មេធាវីការពារក្ដីស្នើសុំឱ្យកោះហៅសាក្សី ជុំ ភួត (2-TCW-1058) ឱ្យមកផ្ដល់សក្ខីកម្មអំពីការបះបោរនៅក្នុងភូមិភាគពាយ័ព្យ[116]។ ដូចបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះក៏បានស្ដាប់សក្ខីកម្មសាក្សីជាច្រើនរូបរួចមកហើយ ដែលបានផ្ដល់ភ័ស្ដុតាងពាក់ព័ន្ធនឹងក្រុមផ្ទៃក្នុង ហើយបានយល់ព្រមតាមសំណើសុំស្ដាប់សក្ខីកម្ម ជាល ជឿន (2-TCW-960) និង ឡុង វុន (2-TCW-971) ពាក់ព័ន្ធនឹងស្ថានភាព និងការបោសសម្អាតនៅក្នុងភូមិភាគពាយ័ព្យ។ ទោះបីជាដូច្នេះក្ដី អង្គជំនុំជម្រះយល់ឃើញថា វាជាប្រយោជន៍នៃយុត្តិធម៌ក្នុងការកោះហៅសាក្សីភូមិភាគពាយ័ព្យដែលពាក់ព័ន្ធបំផុតដើម្បីផ្ដល់ឱកាសបន្ថែមឱ្យ នួន ជា បង្ហាញពីទ្រឹស្ដីនៃការការពារក្ដីរបស់ខ្លួន។ ក្រោយពីបានពិនិត្យមើលឯកសាររបស់សាក្សីទាំង ៥ រូប អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មដែលបានស្នើឡើងទាក់ទងនឹងសាក្សី ឈន វន (2-TCW-1036) និង ហួន ជឿម (2-TCW-1037) មានភាពពាក់ព័ន្ធបំផុត ហើយអាចជួយដល់ការស្វែងរកការពិត។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំស្ដាប់សក្ខីកម្មសាក្សីទាំងនេះ។ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មដែលបានស្នើឡើងទាក់ទងនឹង

---

113 ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ (វ៉ាន់ ម៉ាត់) ទំព័រ ៥០។

114 *សូមមើល* ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ (ម៉ី សាវឿន) ទំព័រ ២១-២២។

115 សំណើសុំលើកទីបី កថាខណ្ឌ ២៦-២៨។ អង្គជំនុំជម្រះបានដកចេញសាក្សី ទាត់ ធឿន (2-TCW-829) ដោយសារសាក្សីរូបនេះបានទទួលមរណភាពរួចហើយ។

116 សំណើសុំលើកទីប្រាំ កថាខណ្ឌ ២៨។

សាក្សីទាំង ៣ រូប ដែលនៅសេសសល់[117] គឺជាភ័ស្តុតាងច្រំដែលច្រើនជាមួយនឹងភ័ស្តុតាងដែលមានរួចហើយនៅក្នុងសំណុំរឿង ជាពិសេសមេធាវីការពារក្តីបានកត់សម្គាល់ថាចម្លើយជាលាយលក្ខណ៍អក្សររបស់ពួកគេត្រូវបានទទួលយកជាឯកសារភ័ស្តុតាងរួចហើយ[118]។ អង្គជំនុំជម្រះយល់ឃើញថា ការស្តាប់សក្ខីកម្មសាក្សីទាំងនេះ នឹងមិនមែនជាប្រយោជន៍នៃយុត្តិធម៌នោះទេ ដោយកត់សម្គាល់បន្ថែមទៀតអំពីដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធី។

៤០. នៅក្នុងសំណើទីប្រាំ មេធាវីការពារក្តីក៏បានស្នើសុំឱ្យកោះហៅសាក្សី ២ រូប បន្ថែមទៀតដើម្បីផ្តល់ភ័ស្តុតាងអំពីអ្នកទោសដែលត្រូវបានគេដោះលែងពីមន្ទីរសន្តិសុខ ស-២១។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អង្គជំនុំជម្រះបានស្តាប់ភ័ស្តុតាងជាច្រើនរួចហើយ ដែលទូទៅពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការដោះលែងអ្នកទោសពីមន្ទីរសន្តិសុខ ស-២១ *ក្នុងនោះ* តាមរយៈសក្ខីកម្មរបស់សាក្សី ប្រាក់ ខន (2-TCW-931),[119] សួស ធី (2-TCW-816)[120] និង កាំង ហ្កេកអ៊ាវ (2-TCW-916)[121]។ ដែលជាទូទៅ វានាំឱ្យមានការច្រានចោលភ័ស្តុតាងដែលបានស្នើសុំ ដោយសារវាជាភ័ស្តុតាងច្រំដែល។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះយល់ឃើញថា វាជាប្រយោជន៍នៃយុត្តិធម៌ដើម្បីផ្តល់ឱកាសបន្ថែមឱ្យមេធាវីការពារក្តី នួន ជា បង្ហាញពីទ្រឹស្តីនៃការការពារក្តីរបស់ខ្លួន។ ក្នុងន័យនេះ អង្គជំនុំជម្រះបានជ្រើសរើសសាក្សី ទេស អុល (2-TCW-1060) ឱ្យមកផ្តល់សក្ខីកម្ម។ អង្គជំនុំជម្រះយល់ឃើញថា ការស្តាប់សក្ខីកម្មសាក្សី ស្រេង ធី (2-TCW-1061) ក៏មិនមានយុត្តិកម្មក្នុងន័យជាប្រយោជន៍នៃយុត្តិធម៌ដូចគ្នា។ ចំណុចចុងក្រោយ សាក្សីលេខ ៤ (2-TCW-1052) មិនត្រូវបានកំណត់អត្តសញ្ញាណឱ្យបានជាក់លាក់ដើម្បីកោះហៅ ឬ ដើម្បីឱ្យអង្គភាពគាំពារសាក្សី និងអ្នក

[117] សាម៉ី សារ៉ែង (2-TCW-1038), ឈួម សារ៉ឺន (2-TCW-1039) និង ឈន វន (2-TCW-1036)។

[118] *សូមមើល* សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យទទួលយកចម្លើយសាក្សីចំនួន ៦ និងឧបសម្ព័ន្ធមួយពាក់ព័ន្ធនឹងសំណុំរឿង 00២/0២ អនុលោមតាមវិធាន ៨៧(៤) ឯកសារ E319/30/1 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ (សម្ងាត់)។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង ឈុំ ភួត ឯកសារ E3/9009 ចុះថ្ងៃទី 0៧ ខែ ធ្នូ ឆ្នាំ ២០១០ (សម្ងាត់)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ (ឡូត សួយ) ទំព័រ ៨-១១, ១៦, ៦២-៦៤។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ (មុន មុត) ទំព័រ ២១-២៤, ៣១-៣៣, ៤១-៤២ (អសាធារណៈ)។

[119] *សូមមើល* ប្រតិចារឹក ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ (ប្រាក់ ខន) ទំព័រ ២៤-២៥។

[120] *សូមមើល* ប្រតិចារឹក ថ្ងៃទី 0២ ខែ មិថុនា ឆ្នាំ ២០១៦ (សួស ធី) ទំព័រ ១០, ៥៩។

[121] *សូមមើល* ប្រតិចារឹក ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៦ (កាំង ហ្កេកអ៊ាវ) ទំព័រ ៧៧-៧៩, ៨១-៨២។ ប្រតិចារឹក ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ (កាំង ហ្កេកអ៊ាវ) ទំព័រ ៥៦-៦០។ *សូមមើលផងដែរ* ឯកសារ E3/10264, ឯកសារ E3/3992 និង ឯកសារ E3/2285។

ជំនាញរកគាត់ឃើញក្នុងគោលបំណងធ្វើការវាយតម្លៃអំពីហានិភ័យនោះទេ ហើយកិច្ចខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះក្នុងការស្វែងរកព័ត៌មានពីអត្តសញ្ញាណរបស់សាក្សីរូបនេះក៏មិនបានទទួលលទ្ធផលផងដែរ[122]។ ហេតុដូច្នេះ អង្គជំនុំជម្រះច្រានចោលសំណើសុំទាំងពីរទាក់ទងនឹងសាក្សីលេខ ៤ (2-TCW-1052)។

៤១. សំណើទីបី រួមបញ្ចូលសំណើសុំពន្លឿនការស្តាប់សក្ខីកម្ម Robert Lemkin (2-TCW-877), ចាន់ សារុត (2-TCW-959) និង អ៊ិន ធឿន (2-TCW-961)។ ទោះបីជាសំណើពីមុន សុំឱ្យកោះហៅសាក្សីទាំងនេះបានធ្វើឡើងទាន់ពេលក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចស្វែងរក ចាន់ សារុត (2-TCW-959) ឃើញឡើយ[123] ហើយអង្គជំនុំជម្រះពិចារណាឃើញថា សក្ខីកម្មរបស់ អ៊ិន ធឿន (2-TCW-961) មានលក្ខណៈច្រំដែលជាមួយនឹងភ័ស្តុតាងដែលផ្តល់ដោយសាក្សី ជាល ជឿន (2-TCW-960) ដែលអង្គជំនុំជម្រះបានជ្រើសរើសឱ្យមកផ្តល់សក្ខីកម្មសម្រាប់ប្រធានបទស្តីពីការបោសសម្អាតផ្ទៃក្នុង។ លើសពីនេះទៀត អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អត្តសញ្ញាណរបស់ អ៊ិន ធឿន (2-TCW-961) ដែលជាបុគ្គលត្រូវបានសម្ភាសនៅក្នុងសៀវភៅដែលមានចំណងជើងថា *នៅពីក្រោយវាលពិឃាត* មិនមានលក្ខណៈច្បាស់លាស់នោះទេ[124]។ ចំពោះ Robert Lemkin (2-TCW-877) អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សម្ភារៈដើមរបស់គាត់ និងសម្ភារៈរបស់អ្នកដទៃដែលអង្គជំនុំជម្រះតុលាការកំពូលទទួលបានពីគាត់ទាក់ទងនឹងការអះអាងរបស់មេធាវីការពារក្តីថា ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យបានបែកខ្ញែកជាក្រុមជម្លោះ ពោលគឺ ការប៉ុនប៉ងរបស់ រស់ ញឹម ក្នុងការផ្តួលរំលំការដឹកនាំរបស់ ប៉ុល ពត និង នួន ជា នៅក្នុង ប.ក.ក.។ ក្រោយពីបានសម្រេចយល់ព្រមតាមសំណើសុំស្តាប់សក្ខីកម្ម ឈន វន (2-TCW-1036), ហួន ជឿម (2-TCW-

[122] *សូមមើល* ចម្លើយតបរបស់ Lemkin ឯកសារ E29/489/1។

[123] របាយការណ៍របស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញទាក់ទងនឹងសាក្សី ចាន់ សារុត (ឯកសារ F2/4/3/3/6.2) ឯកសារ E29/490 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៦ (សម្ងាត់)។ *សូមមើលផងដែរ* សេចក្តីសម្រេចអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងលើសំណើរបស់ នួន ជា សុំឱ្យទទួលយកឯកសារពាក់ព័ន្ធនឹងលោក ROBERT LEMKIN (2-TCW-877) និងសំណើសុំពាក់ព័ន្ធចំនួនពីរទៀតអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ឯកសារ E416/4 ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៦ កថាខណ្ឌ ២៦ *ដែលដកស្រង់* របាយការណ៍លើកទីពីរឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីបញ្ជាក់ឱ្យប្រាកដថាសាក្សី ចាន់ សារុត គឺជាសាក្សីពិតប្រាកដដែលបានផ្តល់បទសម្ភាសន៍នៅក្នុងប្រតិចារឹក (F2/4/3/3/6.2) ឯកសារ E29/490/1 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ (សម្ងាត់)។

[124] *សូមមើល* ចម្លើយតបរបស់ Rob Lemkin ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E29/489/1 ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៦។

1037) និង ម៉ី សាវឿន (2-TCW-1040) លើប្រធានបទដូចគ្នានេះ អង្គជំនុំជម្រះពិចារណាឃើញថា សក្ខីកម្មរបស់ Robert Lemkin (2-TCW-877) មានប្រយោជន៍បន្ថែមតិចតួចប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានពិចារណាយ៉ាងត្រឹមត្រូវទៅលើការខ្វះកិច្ចសហការជាទូទៅពី Robert Lemkin (2-TCW-877) ជាមួយនឹង អ.វ.ត.ក. រួមទាំងករណីសាក្សីរូបនេះបដិសេធមិនផ្តល់ឈុតវីដេអូរបស់គាត់ដែលអង្គជំនុំជម្រះបានស្នើសុំផងដែរ[125]។ អង្គជំនុំជម្រះបានពិចារណាបន្ថែមទៀតថា ដោយសារតែ Robert Lemkin (2-TCW-877) មិនមែនជាសាក្សីអង្គហេតុ ហើយគាត់អាចផ្តល់សក្ខីកម្មបានតែលើហេតុការណ៍ដែលនិយាយតៗគ្នា និងមិនអាចនិយាយភាសាខ្មែរបាននោះ កិច្ចសម្ភាសន៍របស់គាត់បានធ្វើឡើងតាមរយៈ ថេត សម្បត្តិ (2-TCW-885) ដែលជាអ្នកសួរសំណួរ និងអ្នកបកប្រែចម្លើយឲ្យ ហើយអង្គជំនុំជម្រះគ្មានវិធីផ្ទៀងផ្ទាត់ការបកប្រែ ឬ ប្រតិចារឹកដែលបានផលិតឡើងនោះទេ។ ជាក់ស្តែង ករណីនេះប៉ះពាល់ទៅលើតម្លៃជាភ័ស្តុតាងនៃឯកសារដែលបានលើកឡើង និងលើសក្ខីកម្មរបស់គាត់ដែលស្នើឡើង[126]។ ហេតុដូច្នេះ អង្គជំនុំជម្រះច្រានចោលសំណើសុំស្តាប់សក្ខីកម្មសាក្សីទាំង ៣ រូប នេះ។

៤២. ចំពោះសំណើទីបួន ទោះបីជាបានធ្វើឡើងទាន់ពេលវេលាក៏ដោយ ក៏សំណើនេះសុំឱ្យកោះហៅសាក្សីថ្មីចំនួន ២ រូប មកផ្តល់សក្ខីកម្មលើប្រធានបទដូចគ្នា ជាពិសេស អំពីយថាភាព និងភាពអាចជឿទុកចិត្តបាននៃបញ្ជីឈ្មោះអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស.។ ដោយពិចារណាឃើញថា ហ៊ិន សុធានី (2-TCW-1042) គឺជាអ្នកវិភាគដែលបានពិនិត្យមើលឯកសារជាភាសាខ្មែរ អង្គជំនុំជម្រះយល់ឃើញថា វាមានភាពសមស្របជាងក្នុងការកោះហៅបុគ្គលរូបនេះឱ្យមកផ្តល់សក្ខីកម្ម ហើយអង្គជំនុំជម្រះយល់ឃើញថា សំណើសុំស្តាប់សក្ខីកម្ម Hiroto FUJIWARA (2-

[125] សេចក្តីសម្រេចអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង លើសំណើសររបស់ នួន ជា សុំឱ្យទទួលយកឯកសារពាក់ព័ន្ធនឹងលោក ROBERT LEMKIN (2-TCW-877) និងសំណើសុំពាក់ព័ន្ធចំនួនពីរទៀតអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ឯកសារ E416/4 ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៦ កថាខណ្ឌ ២៤-២៥។

[126] *សូមមើលផងដែរ* សេចក្តីសម្រេចអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងលើសំណើសររបស់ នួន ជា សុំឱ្យទទួលយកឯកសារពាក់ព័ន្ធនឹងលោក ROBERT LEMKIN (2-TCW-877) និងសំណើសុំពាក់ព័ន្ធចំនួនពីរទៀតអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ឯកសារ E416/4 ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៦ កថាខណ្ឌ ១៩, ២៤-២៥។ ករណីនេះបានដោះស្រាយសំណើសុំសំខាន់មួយដែលបានកត់សម្គាល់នៅក្នុងសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំកោះហៅ ថេត សម្បត្តិ ក្នុងនាមជាសាក្សីអាទិភាព ឯកសារ E335/3 ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥។

TCW-1043) មានលក្ខណៈច្រំដែល[127]។ ទន្ទឹមហ្នឹងនេះ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តីខកខានមិនបានបង្ហាញពីភាពចាំបាច់ក្នុងការស្តាប់សក្ខីកម្មសាក្សី នួន ម៉ាលី (2-TCW-1044)។ ទោះបីជាមេធាវីការពារក្តីបង្ហាញកង្វល់អំពីវិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការបង្កើតបញ្ជីឈ្មោះអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស. ក៏ដោយ ក៏មេធាវីការពារក្តីខកខានមិនបានពន្យល់អំពីមូលហេតុដែលខ្លួនសួរដេញដោលពីយថាភាព និងដំណើរការនៃការរក្សាទុករូបថតមន្ទីរ ស-២១ ដូចបានរៀបរាប់នៅក្នុងលិខិតក្រមដែលបានទទួលយកជាឯកសារភ័ស្តុតាង មានលេខ E3/9214 នោះដែរ។ អង្គជំនុំជម្រះសូមរម្លឹកថា គ្មានភាគីណាមួយបានលើកឡើងពីការជំទាស់ទៅនឹងការទទួលយករូបថតមន្ទីរ ស-២១ ធ្វើជាភ័ស្តុតាងនោះទេ[128]។ លើសពីនេះទៀត នៅពេលមេធាវីការពារក្តី នួន ជា បានប្រើប្រាស់រូបថតទាំងនេះនៅក្នុងតុលាការ ក្នុងអំឡុងពេលសួរដេញដោលទៅសាក្សី មេធាវីការពារក្តីបានបញ្ជាក់យថាភាពលើរូបថតទាំងនេះតាមរយៈបុគ្គលិកសំខាន់ ២ រូបរបស់មន្ទីរសន្តិសុខ ស-២១[129]។ ត្រង់ចំណុចដែលសក្ខីកម្មរបស់ នួន ម៉ាលី (2-TCW-1044) អាចមានភាពពាក់ព័ន្ធទៅនឹងការអះអាងរបស់មេធាវីការពារក្តីនោះគឺ បុគ្គលភាគច្រើនដែលត្រូវបានចោទប្រកាន់ថាបានចុះឈ្មោះនៅមន្ទីរ ស-២១ មិនត្រូវបានឃុំខ្លួន និងសម្លាប់ចោលនៅទីនោះទេ[130] អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់គាត់មានលក្ខណៈច្រំដែលជាមួយនឹងភ័ស្តុតាងដែលមានរួចហើយនៅក្នុងសំណុំរឿង រួមទាំង សក្ខីកម្មរបស់សាក្សី ហ៊ិន សុផានី (2-TCW-1042) ផងដែរ។

**យោងតាមសំអាងហេតុដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច៖**

[127] ឧបសម្ព័ន្ធ ១៖ អនុស្សរណៈអន្តរការិយាល័យពាក់ព័ន្ធនឹង "បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស. និងការពន្យល់អំពីវិធីសាស្ត្រដែលបានអនុវត្ត" ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E393.1 ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥។

[128] *សូមមើល* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកជាឯកសារភ័ស្តុតាងនូវរូបថត ដែលបានកំណត់អត្តសញ្ញាណថាជារូបថតនៅមន្ទីរសន្តិសុខ ស-២១ នៅក្នុងបញ្ជីពាក់ព័ន្ធដែលត្រូវបានទទួលយកជាឯកសារភ័ស្តុតាង (E3/9214) ឯកសារ E394/1 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦។

[129] *សូមមើល* ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៦ (សួស ធី) ទំព័រ ៨៩-៩៣។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦ (នឹម អ៊ឹម) ទំព័រ ៣៧-៤២។

[130] សំណើសុំលើកទីបួន កថាខណ្ឌ ៤។

**យល់ព្រម** តាមសំណើសុំស្តាប់សក្ខីកម្ម ជាល ជឿន (2-TCW-960), ហួន ជឿម (2-TCW-1037), ឈន វន (2-TCW-1036), សេម អំ (2-TCW-1031), ឡុង វុន (2-TCW-971), ទេស អុល (2-TCW-1060), ស្មួយ សៅ (2-TCW-1029), នឹម គឹមស្រ៊ាង (2-TCW-854), មាស សឿន (2-TCW-917) និង ម៉ី សារឿន (2-TCCP-1040)។

**សូមរម្លឹកឡើងវិញថា** ទាត់ ធឿន (2-TCW-829), ម៉ម ណៃ (2-TCW-864), អន សុភាព (2-TCW-1041) និង លី ហ៊ី (2-TCW-956) បានទទួលមរណភាពហើយ ហេតុនេះសំណើសុំកោះហៅសាក្សីទាំងនេះ ត្រូវទុកជាមោឃៈ។

**កត់សម្គាល់ថា** អង្គជំនុំជម្រះបានស្នើសុំព័ត៌មានពី Walter HEYNOWSKI (2-TCW-946) ពីការដឹងឮរបស់សាក្សីរូបនេះ អំពីឯកសារពាក់ព័ន្ធជំនួសឲ្យការស្តាប់សក្ខីកម្មរូបគាត់។

**សូមរម្លឹកឡើងវិញថា** អង្គជំនុំជម្រះបានរក្សាសេចក្តីសម្រេចរបស់ខ្លួនលើករណីថាតើគួរស្តាប់ ឬមិនគួរស្តាប់សក្ខីកម្ម ហេង សំរិន (2-TCW-831), អ៊ុក ប៊ុនឈឿន (2-TCW-951) និង ប៉ុល សារឿន (2-TCW-962) ហើយក្រោយមក អង្គជំនុំជម្រះបានបដិសេធសំណើសុំស្តាប់សក្ខីកម្មសាក្សីទាំងនេះនៅក្នុងឯកសារលេខ E454។

**សូមរម្លឹកឡើងវិញថា** អង្គជំនុំជម្រះបានរក្សាសេចក្តីសម្រេចរបស់ខ្លួនលើករណីថាតើគួរស្តាប់ ឬមិនគួរស្តាប់សក្ខីកម្ម ហ៊ិន សុធានី (2-TCW-1042) ហើយក្រោយមក អង្គជំនុំជម្រះបានយល់ព្រមតាមសំណើសុំស្តាប់សក្ខីកម្មសាក្សីរូបនេះ និង

**បដិសេធ** សំណើសុំដែលនៅសេសសល់ផ្សេងទៀត។

ភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០១៧

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**